00152308

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៦-អ.វ.ត.ក 01-011-C

**ដាក់ទៅ:** អង្គបុរេជំនុំជម្រះ

**ថ្ងៃដាក់:** ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៧

**ភាគីអ្នកដាក់:** មេធាវីរបស់លោក នួន ជា

**ភាសាដើម:** អង់គ្លេស

**ប្រភេទឯកសារ:** សាធារណៈ

**បានថតចំលងត្រឹមត្រូវតាមច្បាប់ដើម**
**Certified Copy/Copie Conforme**
ថ្ងៃទី(On/Le) 14 ខែ(Month/Mois) Nov
ឆ្នាំ (Year/Année) 2007
ក្រឡាបញ្ជី/ Greffier NUP SOTHUN VICHET

---

**សារណារបស់លោក នួន ជា ដើម្បីគាំទ្រដល់**
**បណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាសម្រេចឃុំខ្លួន**

---

<u>អ្នកដាក់ឯកសារ:</u>

**មេធាវីរបស់លោក នួន ជា**

លោកមេធាវី សុន អរុណ

លោកមេធាវី Michiel PESTMAN

លោកមេធាវី Victor KOPPE

លោក Andrew IANUZZI

<u>អ្នកទទួលឯកសារ:</u>

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន៍យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ORIGINAL DOCUMENT RECEIVED AT 15:19'
BY NUP SOTHUNVICHET
ON 13/11/2007
VICHET
ACTING CASE FILE OFFICER

## I. សេចក្តីផ្តើម

1. អនុលោមទៅតាមវិធាន ៦៣(៤) និង៧៤ (៣)នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា“វិធានផ្ទៃក្នុង”) មេធាវីការពារក្តីរបស់ជនត្រូវចោទ ឈ្មោះ **នួន ជា** (ហៅថា “មេធាវីការពារក្តី”) សូមដាក់សារណា ដើម្បីគាំទ្រដល់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងលើដីកាសម្រេចបង្គប់ឱ្យឃុំខ្លួនបណ្តោះអាសន្ន (ហៅថា “ដីកាសម្រេចឃុំខ្លួន”) ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា“ក.ស.ច.ស”)[1] ។ ដោយមូលហេតុដូចបានរៀបរាប់ខាងក្រោមនេះ មេធាវីការពារក្តីស្នើសូមអង្គបុរេជំនុំជម្រះមេត្តាចេញដីកាសម្រេចបដិសេធចោល ដីកាសម្រេចឃុំខ្លួន ព្រមទាំង (ក)ដោះលែងដោយមានល័ក្ខខ័ណ្ឌ លោក **នួន ជា** ជាបន្ទាន់ ឬ (ខ) បើកសវនាការលើរឿងក្តីឡើងវិញ ដោយគោពទៅតាមសិទ្ធិជាមូលដ្ឋានរបស់គាត់ និងគោលការណ៍ច្បាប់។

## II. សេចក្តីសង្ខេបអំណះអំណាង

2. វិធាន ៦៣(១) សវនាការតទល់គ្នា (ហៅថា“សវនាការអំពីការឃុំខ្លួន”)បានប្រព្រឹត្តឡើង ដោយរំលោភលើសិទ្ធិរបស់លោក **នួន ជា** ក្នុងការទទួលបានទីប្រឹក្សាពិគ្រោះយោបល់ ដូចមានចែងក្នុងវិធានផ្ទៃក្នុង និងនិយាមច្បាប់អន្តរជាតិ។ ទោះបីជាមានមេធាវីម្នាក់ត្រូវបានតែងតាំង ដើម្បីតំណាងឱ្យរូបគាត់ក៏ពិតមែន តែលោក **នួន ជា** បានលះបង់សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវជំនួយផ្នែកច្បាប់នៅក្នុងសវនាការអំពីការឃុំខ្លួន។ ដោយពិចារណាលើការខាកខានរបស់ ក.ស.ច.ស ក្នុងការពន្យល់អំពីផលវិបាកនៃការកលះបង់សិទ្ធិនេះ និងស្ថានភាពសុខភាពដ៏ទន់ខ្សោយរបស់លោក **នួន ជា** នៅពេលនោះ ការលះបង់សិទ្ធិនេះ ត្រូវចាត់ទុកជាមោឃៈតាមផ្លូវច្បាប់។ សេចក្តីសម្រេចរបស់ ក.ស.ច.ស ក្នុងការ

[1] ឯកសារលេខ C-9។ កាលពីថ្ងៃទី២៥ តុលា ២០០៧ អង្គបុរេជំនុំជម្រះបានចេញដីកាបង្គាប់ឱ្យដាក់សារណាដោយបង្គាប់ “នួន ជា (...) ដាក់សារណាដើម្បីធ្វើយុត្តិកម្ម និងការពារផលប្រយោជន៍របស់ខ្លួន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន (...) ក្នុងអម្លុងពេល១៥ថ្ងៃ ចាប់ពីថ្ងៃទទួលដីកាបង្គាប់នេះតទៅ និងដាក់ទៅអង្គបុរេជំនុំជម្រះ។” សំណៅមួយច្បាប់នៃដីកាបង្គាប់នេះបានប្រគល់ឱ្យមេធាវីការពារក្តីនៅថ្ងៃទី២៦ តុលា ២០០៧ ដោយអ្នកតំណាងរបស់ផ្នែកគ្រប់គ្រងតុលាការ។

ទទួលយកការលះបង់សិទ្ធិនេះ ហើយបន្តនីតិវិធីសវនាការអំពីការឃុំខ្លួន ដោយអវត្តមានមេធាវីការពារក្តី ប្រព្រឹត្តខុសនឹងនីតិវិធី និងរំលោភបំពានសិទ្ធិជាមូលដ្ឋានជាច្រើនរបស់លោក **នួន ជា** ។

3. ការទាមទារខាងផ្នែកច្បាប់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន ដូចដែលបានកំណត់ក្នុងវិធាន ៦៣(៣) ពុំត្រូវបានបំពេញឡើយ។ ភស្តុតាងដែលចងភ្ជាប់លោក **នួន ជា** ទៅនឹងបទឧក្រិដ្ឋដែលបានបញ្ជាក់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[2] គឺពុំគ្រប់គ្រាន់ឡើយ។ ប៉ុន្តែ ដើម្បីជាប្រយោជន៍ដល់ការវែកញែករកការពិត អត្ថិភាពនៃការសង្ស័យសមហេតុផលថាលោក **នួន ជា** ជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ពុំមានការព្រួយបារម្ភណ៍ដែលមានលក្ខណៈប៉ាន់ស្មានណាមួយធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្ននោះ ត្រូវបានចង្អុលបង្ហាញដោយ ក.ស.ព ឬ ក.ស.ច.សឡើយ។ ដូច្នេះដីកាសម្រេចឃុំខ្លួននេះ ពុំអាចតាំងទៅបានដោយពុំមានភស្តុតាងសម្អាងឡើយ។

## III. **អង្គហេតុ**

4. កាលពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧[3] ក.ស.ច.ស បានចេញដីកាបង្គាប់ឱ្យនាំខ្លួនលោក **នួន ជា**។ ដីកានោះត្រូវបានអនុវត្តដោយនគរបាលយុត្តិធម៌របស់ អ.វ.ត.ក នៅព្រឹកថ្ងៃទី១៩ខែកញ្ញា ឆ្នាំ២០០៧[4]។ ការនាំខ្លួនបានប្រព្រឹត្តទៅឯផ្ទះរបស់លោក **នួន ជា** នៅប៉ៃលិន ជាកន្លែងដែលគាត់បានរស់នៅយ៉ាងស្ងៀមស្ងាត់ និងដោយចំហ ជាមួយភរិយា និងគ្រួសាររបស់គាត់អស់ជាច្រើនឆ្នាំមកហើយ។ ភ្លាមៗនោះលោក **នួន ជា** ត្រូវបាននាំខ្លួនតាមឧទ្ធម្ភាគចក្រមកក្រុងភ្នំពេញ និងបញ្ជូនទៅអគាររបស់អ.វ.ត.ក ក្នុងចន្លោះពេល២ថ្ងៃ រវាងថ្ងៃចេញដីកាបង្គាប់ឱ្យនាំខ្លួន និងការអនុវត្តតាមដីកានោះ លោក **នួន ជា**-ក្នុងវ័យ៨២ឆ្នាំ និងក្នុងស្ថានភាពដ៏ទន់ខ្សោយ - ពុំត្រូវបានផ្តល់លទ្ធភាពឱ្យចូលខ្លួនដោយស្ម័គ្រចិត្តទៅកាន់យុត្តាធិការរបស់ អ.វ.ត.ក[5] ដូចដែលគាត់ធ្លាប់ប្រកាសជាសាធារណៈថា គាត់នឹងចូលខ្លួនឱ្យ អ.វ.ត.ក ។

---

[2] ឯកសារលេខ D-3 ដែលបានដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") កាលពីថ្ងៃទី១៨ កក្កដា ២០០៧។

[3] ឯកសារលេខ C-6 ដីកាបង្គាប់ឱ្យនាំខ្លួន។

[4] ឯកសារលេខ C-7 របាយការណ៍នាំខ្លួនជនសង្ស័យ។

[5] (សូមមើល ឧទាហរណ៍ Jurist Legal News and Research, មហាវិទ្យាល័យច្បាប់នៃសកលវិទ្យាល័យ Pittsburg ចំណងជើងថា "សាលាក្តីខ្មែរក្រហមសង្ឃឹមថានឹងមានកិច្ចសហប្រតិបត្តិការពីបងធំទី ២" ចុះថ្ងៃទី ២០

5. មុនការបង្ហាញខ្លួនលើកដំបូងដែលបានប្រព្រឹត្តនៅម៉ោង២ និង៤០នាទីរសៀល នៅថ្ងៃនាំខ្លួន លោក[6] **នួន ជា** បានជួបក្នុងរយៈពេលខ្លីជាមួយមន្ត្រីរបស់អង្គភាពគាំពារការការពារក្តី (ហៅថា "អ.គ.ក.ក") ។ គាត់បានប្រាប់ពួកគេថា គាត់នឹងចាត់តាំងលោកមេធាវី **សុន អរុណ** ជាមេធាវីកម្ពុជារបស់គាត់ ប៉ុន្តែនាពេលនោះ លោក **សុន អរុណ** កំពុងស្ថិតនៅខេត្តបាត់ដំបង ហើយអាចមកបង្ហាញខ្លួនដើម្បីតំណាងឲ្យលោក **នួន ជា** នៅថ្ងៃបន្ទាប់តែប៉ុណ្ណោះ គឺនៅថ្ងៃទី ២០ ខែកញ្ញា ២០០៧ វេលាម៉ោង ២រសៀល[7] ។

6. នៅពេលបង្ហាញខ្លួនលើកដំបូង លោក **នួន ជា** ត្រូវបានទទួលដំណឹងអំពីបទចោទមកលើរូបគាត់ និងសិទ្ធិរបស់គាត់ក្នុងការទទួលបានជំនួយពីមេធាវី[8]។ គាត់បាននិយាយថា គាត់បានជ្រើសតាំងលោក **សុន អរុណ** ជាមេធាវីកម្ពុជារបស់គាត់រួចហើយ ហើយជាមួយមេធាវីនេះគាត់នឹងពិភាក្សា ដើម្បីជ្រើសរើសរកមេធាវីអន្តរជាតិម្នាក់ទៀត[9]។ បន្ទាប់មក ក.ស.ច.ស៖

> បានប្រាប់ទៅជនត្រូវចោទថា គាត់មានសិទ្ធិក្នុងការនៅស្ងៀម និងអាចមិនឆ្លើយនឹងសំណួរណាមួយបាន ទោះយ៉ាងណាក៏ដោយ ប្រសិនបើគាត់ចង់ធ្វើសេចក្តីថ្លែងការណ៍ណាមួយ យើងនឹងកត់ត្រាទុកភ្លាម ។ យើងបានប្រាប់គាត់អំពីសិទ្ធិរបស់គាត់ ក្នុងការពិគ្រោះ

---

ខែកញ្ញា ២០០៧ ("មន្ត្រីជាន់ខ្ពស់ខ្មែរក្រហម នួន ជា សំដែងពីបំណងសហប្រតិបត្តិយ៉ាងពេញលេញជាមួយ[អ.វ.ត.ក] [...] ចៅក្រមមួយរូបរបស់ អ.វ.ត.ក ប្រាប់សារព័ត៌មានកាលពីថ្ងៃពុធ ។ លោក **យូ ប៊ុនឡេង** ចៅក្រមស៊ើបអង្កេតកម្ពុជានៃ អ.វ.ត.ក ប្រាប់សារព័ត៌មាន Reuter ថា ជា [...] នឹងនិយាយអំពីរបបនៅពេលសវនាការមកដល់ ។ សារព័ត៌មាន Gulf Times ចំណងជើងថា"មេដឹកនាំខ្មែរក្រហមបដិសេធពីតួនាទីក្នុងអំពើសាហាវកាប់សម្លាប់" ចុះថ្ងៃទី ២១ ខែកក្កដា ២០០៧ ("ខ្ញុំត្រៀមខ្លួនរួចជាស្រេច និយាយប្រាប់ នៅពេលតុលាការតុលាការកោះហៅរូបខ្ញុំ") ។ ព្រឹតិប័ត្រ The Chicago Tribune ("បទសំភាសចុងក្រោយជាមួយ **នួន ជា**-បងធំទី ២នៃកម្ពុជាប្រជាធិបតេយ្យ") ចុះនៅថ្ងៃទី ១៦ ខែកុម្ភះ ២០០៧ ("យើងត្រូវតែទៅតុលាការ ដើម្បីតតាំង") **នួន ជា** និយាយថា ខ្ញុំនឹងទៅដើម្បីពន្យល់គេឲ្យយល់ តើមានអ្វីកើតឡើង") ។ ព្រឹត្តិប័ត្រ Cambodia Daily ក្រោមចំណងជើងថា ("**នួន ជា** និយាយថាគាត់ត្រៀមខ្លួនចូលពន្ធនាគារ" ចុះថ្ងៃទី ២ខែសីហា ២០០៦( **នួន ជា** និយាយ [...] ថាគាត់ត្បៀមខ្លួនការពារ") ។

[6] ឯកសារលេខ D-20 របាយការណ៍ជាលាយល័ក្ខអក្សរអំពីការបង្ហាញខ្លួនលើកដំបូង។

[7] អង្គហេតុទាំងនេះត្រូវបានឲ្យដំណឹងទៅ ក.ស.ច.ស ជាលាយល័ក្ខអក្សរភ្លាមៗ។ សូមមើលឯកសារលេខ A-28 លិខិតរបស់ អ.គ.ក.កផ្ញើទៅក.ស.ច.ស ចុះថ្ងៃទី១៩ កញ្ញា ២០០៧។

[8] ឯកសារលេខ D-20 របាយការណ៍ជាលាយល័ក្ខអក្សរអំពីការបង្ហាញខ្លួនលើកដំបូង ទំព័រ ២-៣។

[9] ដូចគ្នា នៅទំព័រ ៣។

យោបល់ជាមួយមេធាវីរបស់គាត់ មុននឹងសួរចម្លើយ និងសិទ្ធិសំណូមពរឱ្យមេធាវីរបស់គាត់មានវត្តមាននៅពេលដែលគាត់ធ្វើសេចក្តីថ្លែងការណ៍[10] ។

លោក **នួន ជា** បានគូសបញ្ជាក់ថា គាត់"ចង់ធ្វើសេចក្តីថ្លែងការណ៍មួយ បើទោះជាអវត្តមានមេធាវី (របស់គាត់)ក៏ដោយ" ហើយនីតិវិធីក៏បន្តទៅមុខទៀត[11]។ក្រោយមកលោក **នួន ជា** ត្រូវបានផ្តល់ប្រឹក្សាថាសវនាការតទល់គ្នាអាចនឹងរៀបចំឡើង ដើម្បីដោះស្រាយបញ្ហាអំពីការឃុំខ្លួនបណ្តោះអាសន្ន[12]។ គាត់បានឆ្លើយថា "ទោះបីជាមេធាវីរបស់ខ្ញុំពុំទាន់មានវត្តមាននៅឡើយក៏ដោយ ក៏ខ្ញុំចង់ឱ្យសវនាការតទល់គ្នានេះរៀបចំឡើងភ្លាមៗ"[13]។

7. នៅម៉ោង៤ និង២៥នាទីរសៀលនាថ្ងៃដដែលនោះ សវនាការអំពីការឃុំខ្លួននេះបានប្រព្រឹត្តឡើង[14]។ ជាថ្មីម្តងទៀត លោក **នួន ជា** ត្រូវបានជូនដំណឹងថា "សេចក្តីសម្រេចទាក់ទងនឹងការឃុំលើរូបគាត់នេះអាចត្រូវបានធ្វើឡើងតែ បន្ទាប់ពីសវនាការតទល់គ្នានេះតែប៉ុណ្ណោះ"[15]។ទោះជាយ៉ាងណាក៏ដោយ គាត់ពុំត្រូវបានផ្តល់ប្រឹក្សាជាពិសេស អំពីសិទ្ធិរបស់គាត់ក្នុងការនៅស្ងៀមមិនឆ្លើយតបនៅក្នុងសវនាការអំពីការឃុំខ្លួននោះឡើយ ឬក៏បានបង្ហាញយ៉ាងច្បាស់តាមរយៈរបាយការណ៍ជាលាយល័ក្ខអក្សរថាគាត់ត្រូវបានប្រាប់យ៉ាងច្បាស់លាស់ថា សិទ្ធិមានមេធាវីរបស់គាត់ ក៏ត្រូវអនុវត្តដូចគ្នាដែរនៅក្នុងពេលសវនាការអំពីការឃុំខ្លួន ដែលជាដំណាក់កាលតាមច្បាប់មួយនៃនីតិវិធីផ្សេងអំពីការបង្ហាញខ្លួនជាលើកដំបូង[16]។ ក្នុងស្ថានការណ៍ណាមួយនៅក្នុងដំណាក់កាលនេះ ក.ស.ព បានស្នើសុំៈ

ឱ្យមាន*ការពន្យល់យ៉ាងច្បាស់លាស់*ទៅដល់ជនត្រូវចោទ អំពីសវនាការតទល់គ្នា ពីព្រោះជាដំបូងគាត់បានសំណូមពរឱ្យមានមេធាវី បន្ទាប់មកទៀតគាត់បែរជានិយាយ

---

[10] ដូចគ្នា នៅទំព័រ ៤។

[11] ដូចគ្នា នៅទំព័រ ៤។

[12] ដូចគ្នា នៅទំព័រ ៤។

[13] ដូចគ្នា នៅទំព័រ ៤។

[14] ឯកសារលេខ C-8 របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ទំព័រ១។

[15]ដូចគ្នា នៅទំព័រ ២។

[16] ទាំងអស់នេះដែលអាចត្រូវបានប្រមូលជាស្ថាពរអំពីរបាយការណ៍ជាលាយល័ក្ខអក្សរគឺថា ក.ស.ច.សបានកត់សម្គាល់លើអង្គហេតុដែលលោក សុន អរុណពុំមានពេលទំនេរ ហើយលោកនួន ជា ចង់ឱ្យដំណើរការនីតិវិធីឡើងដោយពុំមានវត្តមានរបស់មេធាវីគាត់។ សូមមើលឯកសារលេខ C-8របស់ក.ស.ច.សចុះថ្ងៃទី២០ កញ្ញា ២០០៧។ សូមមើលឯកសារលេខ D-21 អំពីសេចក្តីសម្រេចទទួលស្គាល់មេធាវី។

ថា ពុំចាំបាច់មានមេធាវីសម្រាប់សវនាការនេះទេ។ ដូច្នេះ គាត់ត្រូវទទួលបានការពន្យល់យ៉ាងច្បាស់លាស់ ដើម្បីធានាថា គាត់បាន*យល់ច្បាស់*អំពីគោលបំណង និងនីតិវិធីច្បាប់សម្រាប់សវនាការតទល់គ្នានេះ[17]។

លោកចៅក្រម **យូ ប៊ុនឡេង** បានកត់សម្គាល់ថាលោក **នួន ជា** បានទទួលដំបូន្មានពីលោកចៅក្រម Le Monde រួចហើយៗ គាត់ក៏បាននិយាយថា គាត់ពុំត្រូវការមេធាវីទេ[18]។ បន្ទាប់មកលោក **នួន ជា** បាននិយាយថា៖ "បាទ ពិតមែនហើយ។ ខ្ញុំចង់បានមេធាវី ប៉ុន្តែខ្ញុំមិនទាមទារឲ្យមានវត្តមានមេធាវីរបស់ខ្ញុំនៅពេលនេះឡើយ។ នៅពេលនេះខ្ញុំអាចការពារខ្លួនឯងបាន។ ចាប់ពីថ្ងៃស្អែកតទៅ ខ្ញុំនឹងមានមេធាវីការពារខ្លួនខ្ញុំ"[19]។ បន្ទាប់មកសវនាការបានចាប់ផ្តើមនីតិវិធី ដោយពុំបានធ្វើការបំភ្លឺទៅតាមសំណើសុំរបស់ ក.ស.ព ឡើយ។

8. នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក.ស.ព បានលើកឡើងថា "ល័ក្ខខ័ណ្ឌតម្រូវដើម្បីចាប់ខ្លួន និងឃុំខ្លួនជាបណ្តោះអាសន្ន (...) លោក **នួន ជា** (...) ដូចដែលបានចែងនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក" ត្រូវបានបំពេញ[20]។ ជាពិសេសទៀត ក៏បានបញ្ជាក់ថា មានហេតុផលដែលអាចឲ្យជឿបានថា លោក **នួន ជា** បានប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ[21]។ ជាងនេះទៅទៀត ក.ស.ព បានលើកឡើងទស្សនីយភាពនៃការគំរាមកំហែង៣គឺ ការរត់គេចខ្លួនពីតុលាការ[22] ការជ្រៀតជ្រែកចូលទៅលើសាក្សី ជនរងគ្រោះ, តតិយជន[23] និងការបង្កបញ្ហាដល់សណ្តាប់ធ្នាប់សាធារណៈ[24]។ អំណះអំណាងដដែលនេះត្រូវបានលើកឡើងម្តងទៀតដោយសហព្រះរាជអាជ្ញា **ជា លាង** នៅក្នុងសវនាការអំពីការឃុំខ្លួន[25]

---

[17] ឯកសារលេខ C-8 របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ទំព័រ២-៣ (ការគូសបញ្ជាក់បន្ថែម)។

[18] ដូចគ្នា នៅទំព័រ ៣។

[19] ដូចគ្នា នៅទំព័រ ៣។

[20] ឯកសារលេខ D-3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខ័ណ្ឌ១១៨។

[21] ដូចគ្នា នៅកថាខ័ណ្ឌ ១១៨(ក)។

[22] ដូចគ្នា នៅកថាខ័ណ្ឌ ១១៨(ខ)។

[23] ដូចគ្នា នៅកថាខ័ណ្ឌ ១១៨(គ)។

[24] ដូចគ្នា នៅកថាខ័ណ្ឌ ១១៨(ឃ)។

[25] ឯកសារលេខ C-8 របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ទំព័រ៣។

ព្រមជាមួយចំនុចបន្ថែមទៀតដែលថា ការខកខានឃុំខ្លួនលោក **នួន ជា** អាចបណ្តាលឲ្យមាន "ការសងសឹកទៅលើរូបគាត់"[26]។

9. ជាការគាំទ្រលើអំណះអំណាងផ្នែកច្បាប់របស់គាត់ លោកស្រី **ជា លាង** បានដាក់សេចក្តីសន្និដ្ឋានដូចខាងក្រោម លោក **នួន ជា** កាន់លិខិតឆ្លងដែន និងរស់នៅក្បែរព្រំដែនប្រទេសថៃ ហើយលើកមុនគាត់ធ្លាប់ទិះទៀនមនុស្សក្រោមបង្គាប់គាត់ថាមិនបានបំផ្លាញភស្តុតាង[27]។ បន្ទាប់មក លោកស្រី **ជា លាង** បានសុំ"ផ្តល់ឯកសារមួយចំនួនសម្រាប់ជាអំណះអំណាង និងជាភស្តុតាង ដើម្បីគាំទ្រលើសំណើសុំនេះ"[28]។ លោកចៅក្រម Le Monde បានគូសបញ្ជាក់ថា ជនត្រូវចោទអាច"ត្រូវការពេលវេលា ដើម្បីសិក្សា(ពីរឿងទាំងនោះ) ជាមុនសិន"[29]។ បន្ទាប់មក របាយការណ៍បានបញ្ជាក់ថា៖ "បន្ទាប់ពីបានទទួលពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន ជនត្រូវចោទ បានបង្ហាញនូវកំណត់សម្គាល់របស់គាត់ដូចខាងក្រោមនេះ និងបានធ្វើសំណូមពរថា៖ ខ្ញុំអាចឆ្លើយបានដោយពុំចាំបាច់អានឯកសារ (...)"[30]។

10. ឆ្លើយតបទៅនឹងការអះអាងរបស់ក.ស.ព **លោក នួន** ជាបានបដិសេធនូវរាល់ការចូលរួមក្នុងសកម្មភាពឧក្រិដ្ឋ[31] និងបានគូសបញ្ជាក់ថាទោះជាខ្លួនធ្លាប់មានសំណាងនឹងធ្វើយ៉ាងដូច្នេះក៏ដោយ ក៏គាត់ពុំមានចេតនានឹងរត់គេច ហើយគាត់មានបំណងចូលរួមក្នុងនីតិវិធីទាំងនេះ[32] គាត់ពុំបំផ្លាញភស្តុតាង[33] ហើយ

---

[26] ដូចគ្នា នៅទំព័រ ៣។

[27] ដូចគ្នា នៅទំព័រ ៣។

[28] ដូចគ្នា នៅទំព័រ ៣។

[29] ដូចគ្នា នៅទំព័រ ៣។

[30] ដូចគ្នានៅទំព័រ ៣។ ទោះជាយ៉ាងណាក៏ដោយ ពុំមាននិទ្ទេសផ្សេងណាមួយនៅក្នុងឯកសារត្រូវបានធ្វើឡើង ទាំងក្នុងរបាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ក៏ដូចជាដីកាសម្រេចឃុំខ្លួន ។ អ្វីដែលច្បាស់លាស់គឺថា លោក នួន ជា ពុំមានពេលគ្រប់គ្រាន់ដើម្បីមើល និងជំទាស់ទៅលើឯកសារទាំងនេះនៅក្នុងសវនាការអំពីការឃុំខ្លួន ។ ឯកសារនោះពុំមាននៅក្នុងសំណើរឿងរបស់ក.ស.ច.ស របស់លោក នួន ជា ដែលមានចំណងជើងថា"ការឃុំខ្លួន និងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ឬដាក់នៅក្នុងសំណុំរឿងនោះនូវឯកសារយោងទៅលើលក្ខណៈ ឬលើទីកន្លែងណាមួយរបស់ពួកវានៅក្នុងសំណុំរឿងដែលធំជាងនេះ។

[31] ឯកសារលេខ C-8 របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ទំព័រ៤។

[32] ដូចគ្នា នៅទំព័រ ៣-៤។

[33] ដូចគ្នា នៅទំព័រ ៤។

គាត់បានធ្វើសម្លាប់រង្គាលកម្មយ៉ាងស្ងប់ស្ងាត់ចូលក្នុងសង្គមកម្ពុជាវិញដែរ[34]។ ម្យ៉ាងទៀត ប្រសិនបើមាននរណាម្នាក់ចង់ធ្វើទុក្ខទោសលើរូបគាត់ ប្រហែលគេធ្វើរួចបាត់ទៅហើយ[35]។

11. ប្រាកដណាស់ ដោយពុំមានការពិភាក្សាជាសារវន្តណាមួយ ចៅក្រមបានឲ្យដំបូន្មានទៅលោក **នួន ជា** ថា គាត់អាចត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ន[36]។ សវនាការអំពីការឃុំខ្លួនត្រូវបានបញ្ចប់នៅម៉ោង ៦ និង៣០នាទីល្ងាច ហើយដីកាសម្រេចឃុំខ្លួនត្រូវបានចេញភ្លាមៗ។ ទាក់ទងនឹងភាពធ្ងន់ធ្ងរនៃភស្តុតាង ក.ស.ច.ស បានយល់ឃើញថា៖"តាមរយៈឯកសារ និងចម្លើយសាក្សីជាច្រើនដែលដាក់បន្ទុកលើលោក **នួន ជា** បង្កើតបានជាហេតុផលដែលអាចឲ្យជឿថា គាត់បានប្រព្រឹត្តបទល្មើសដូចដែលបានដាក់បន្ទុក"[37]។ ចំណុចពាក់ព័ន្ធជាបន្ថែមទៀតត្រូវបានធ្វើយុត្តិកម្មដូចខាងក្រោម៖

1. <u>ការប្រឈមមុខនឹងការរត់គេចខ្លួន</u>៖ "(ព្រោះ) ទោសឧក្រិដ្ឋជាប់មន្ទីរឃុំឃាំងអស់មួយជីវិតដែល **នួន ជា** ត្រូវប្រឈមមុខ អាចនាំឲ្យមានការភ័យខ្លាចថា ជននេះអាចស្វែងរកការគេចខ្លួនពីតុលាការ"[38]។
2. <u>ការជ្រៀតជ្រែកទៅលើសាក្សី</u>៖ "(ការឲ្យ) តួនាទីថានានុក្រមជាពិសេសរបស់ **នួន ជា** ("បងធំទី២"នៃរបបនោះ) នាំឲ្យសង្ស័យថា ប្រសិនបើគាត់នៅមានសេរីភាព ជននេះព្យាយាម និងរៀបចំធ្វើការដាក់សម្ពាធលើសាក្សី និងជនរងគ្រោះ ជាពិសេសអ្នកដែលស្ថិតក្រោមបង្គាប់គាត់"[39]។
3. <u>សណ្ដាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់ខ្លួន</u>៖ "អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល៣០ឆ្នាំក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះ វាមិនមែនការហួសហេតុពេកដែលអះអាងថា នៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសម្ដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហិង្សា ឬអាចប៉ះ

[34] ដូចគ្នា នៅទំព័រ ៣។

[35] ដូចគ្នា នៅទំព័រ ៤។

[36] ដូចគ្នា នៅទំព័រ ៤។

[37] ដីកាសម្រេចឃុំខ្លួន កថាខ័ណ្ឌ ៥។

[38] ដូចគ្នា នៅ កថាខ័ណ្ឌ ៥។

[39] ដូចគ្នា នៅ កថាខ័ណ្ឌ ៥។

ពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់ ដោយសារស្ថានការណ៍ជាក់ស្តែងនៅពេលនេះខុសពីពេលមុន គឺចាប់តាំងពីពេលដែលជនត្រូវចោទត្រូវបានចោទប្រកាន់ជាផ្លូវការរួចមក"[40]។

12. បន្ថែមពីលើ ក.ស.ច.ស បានគូសបញ្ជាក់ថា "មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដែលមានលក្ខណៈតឹងរ៉ឹង និងមានប្រសិទ្ធិភាពអាចធានាឲ្យមានការបំពេញកិច្ចការ ប្រកបដោយប្រសិទ្ធិភាពចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ ហើយថា ការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ ដើម្បីសម្រេចគោលដៅខាងលើនេះ"[41]។ ក្រៅពីការយោងជាទូទៅទៅលើ"ឯកសារ និងចម្លើយសាក្សីជាច្រើនដែលដាក់បន្ទុកលើ **នួន ជា**"[42] ក្នុងដីកាសម្រេចឃុំខ្លួន ពុំមានកន្លែងណាមួយបង្ហាញជាភស្តុតាងគាំទ្រលើការរកឃើញអង្គហេតុដោយប៉ាន់ស្មាននោះឡើយ។

13. នៅថ្ងៃទី១៧ តុលា ២០០៧ មេធាវីការពារក្តីរបស់លោក **នួន ជា** បានដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ មេធាវីអន្តរជាតិត្រូវបានជ្រើសតាំងក្នុងរយៈពេលយ៉ាងខ្លីបន្ទាប់ពីនោះ ហើយបានមកដល់ភ្នំពេញនៅថ្ងៃទី២២ តុលា ២០០៧។

14. នៅព្រឹកថ្ងៃទី ៧ ខែវិច្ឆិកា ២០០៧ ក.ស.ច.ស ផ្តល់ឯកសារមកមេធាវីការពារក្តី ដែលមានចំណងជើងថា"ទឡ្ហីករណ៍ និង ឯកសារបន្ថែមរបស់សហព្រះរាជអាជ្ញា សម្រាប់គាំទ្រលើការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីរបស់ជនសង្ស័យ **នួន ជា**"("ឯកសារបន្ថែម")[43] ។ និទ្ទេសសរសេរដោយដៃនៅលើគំរប បង្ហាញថាក្រឡាបញ្ជីរបស់ ក.ស.ច.ស បានទទួលឯកសារនៅថ្ងៃទី ១៩ ខែកញ្ញា ២០០៧ ។ ប៉ុន្តែសម្ភារៈបន្ថែមនេះ មិនមានលេខលិបិក្រមផ្លូវការទេ ហើយការស្រាវជ្រាវស្វែងរកសំណុំរឿង[44] មិនបានបង្ហាញពីសំណៅរបស់ឯកសារដែលបានតម្កល់ ។ ពុំមានមន្ទិលសង្ស័យចំពោះ "ឯកសារ"ដែលលោក

---

[40] ដូចគ្នា នៅ កថាខ័ណ្ឌ ៥។

[41] ដូចគ្នា នៅ កថាខ័ណ្ឌ ៦។

[42] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក.ស.ច.ស ចុះថ្ងៃទី១៩ កញ្ញា ២០០៧ (ឯកសារលេខ C-9) កថាខ័ណ្ឌ ៥។

[43] ឯកសារបន្ថែមចុះថ្ងៃទី ១៩ ខែកញ្ញា ២០០៧ ដែលកំណត់សំគាល់ថា "សំងាត់" ជាសេចក្តីសន្និដ្ឋានផ្នែកច្បាប់មានកំរាស់ ៧សន្លឹក និងបរិសិដ្ឋគាំទ្រដែលមានកំរាស់ ១២សន្លឹក ។

[44] បច្ចុប្បន្ននេះសំណុំរឿងរក្សានៅបន្ទប់លេខ ១២០នៃអាគាររបស់ អ.វ.ត.ក ។ កំណត់សំគាស់: ការស្រាវជ្រាវរកឯកសារសំណុំរឿងលើកទីមួយ ធ្វើឡើងបន្ទាប់ពីទីប្រឹក្សាបរទេសមកដល់ទីក្រុងភ្នំពេញ ។ នៅពេលការស្រាវជ្រាវបន្ត បន្ទាប់នៅតែបរាជ័យ មេធាវីការពារក្តីបានទំនាក់ទំនងជាមួយក.ស.ច.ស ដើម្បីសួរយោបល់អំពីទីតាំងរបស់ឯកសារ ។ ការស៊ើបសួរនេះនាំឲ្យមានការបញ្ជូនឯកសារបន្ថែមទាក់ទងទៅនឹងការការពារក្តី ដោយក.ស.ច.ស ។

ស្រី **ជា លាង** យោងទៅពេលសវនាការស្ដីពីការឃុំខ្លួនបណ្ដោះអាសន្ន ដែលមេធាវីការពារក្ដីពុំបានពិចារណាថា ឯកសារទាំងនេះ ជាប់ពាក់ពន្ធជាមួយបណ្ដឹងជំទាស់ ដោយសារតែឯកសារនេះពុំបានបង្កើតជាផ្នែកមួយនៃសំណុំរឿងផ្លូវការណាមួយរបស់ អ.វ.ត.ក នៅឡើយទេ ដែលភាគីទាំងអស់មានសិទ្ធិស្មើៗគ្នាក្នុងការពិនិត្យ ។ ប្រសិនបើ ក.ស.ព មានបំណងតម្កល់ឯកសារបន្ថែម ជាមួយសំណើឆ្លើយតបចំពោះសារណាតបរបស់មេធាវីការពារក្ដីគប្បីឆ្លើយតបឲ្យបានសមស្របផងដែរ ។

## IV. ច្បាប់ពាក់ព័ន្ធ

### ក. បទដ្ឋាននៃការពិនិត្យបណ្ដឹងជំទាស់

15. អនុលោមទៅតាមការអនុវត្តនៃប្រព័ន្ធច្បាប់ស៊ីវិលគ្រប់គ្រងលើការប្ដឹងជំទាស់ អង្គបុរេជំនុំជម្រះគប្បីពនិត្យបញ្ហានៃការឃុំខ្លួនបណ្ដោះអាសន្នជាថ្មី ដោយពុំចាំបាច់ពិចារណាទៅលើបញ្ហាផ្លូវច្បាប់ ឬការរកឃើញអង្គហេតុណាមួយរបស់ ក.ស.ច.សឡើយ ។ដើម្បីធ្វើសេចក្ដីសំរេចថ្មី អង្គបុរេជំនុំជម្រះមានឆន្ទានុសិទ្ធិតម្កល់ ច្រានចោល ឬ កែប្រែដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ផ្អែកលើសំណុំរឿង និងព័ត៌មានបន្ថែមណាមួយ ដែលផ្ដល់ដោយភាគីប្ដឹងឧទ្ធរណ៍[45] ។

### ខ. ការអនុវត្តនីតិវិធានទីតិវិធីបង្កើតនៅកំរិតអន្តរជាតិ

16. មាត្រា ៣៣ថ្មីនៃអ.វ.ត.ក ចែងថា:

> អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តទៅឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនជាប់ចោទ និងមានការការពារឲ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី ។ ប្រសិនបើនីតិវិធី ដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬអនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះ ជាមួយបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបង្កើតឡើងនៅកំរិតអន្តរជាតិ ។

---

[45] ដោយសារការអនុវត្តនីបែបនេះបានអនុវត្តនៅតុលាការខេត្ត/ក្រុងនៃប្រទេសកម្ពុជា ហើយស្របតាមបទដ្ឋានអន្តរជាតិផងដែរ ។ ពុំចាំបាច់ពឹងអាស្រ័យលើយុត្តសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ធ្វើជាមគ្គុទេសទេ ។

អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនឹងដំណើរការសមស្របនៃច្បាប់ ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ [the "ICCPR"][46] ។

17. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះមានកាតព្វកិច្ចទទួលស្គាល់នូវនីតិវិធីព្រហ្មទណ្ឌដែលមាននិយាមជាអន្តរជាតិ ដែលផ្អែកទាំងស្រុង ឬមួយផ្អែកលើ ការធានាសិទ្ធិមនុស្សជាមូលដ្ឋាន ដូចដែលបានចែងនៅក្នុងមាត្រា ១៤ និង ១៥នៃ ICCPR[47] ។ វាជាការចាំបាច់ក្នុងការបញ្ចូលនូវយុត្តិសាស្ត្រពាក់ព័ន្ធរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត[48] និង ស្ថាប័នសិទ្ធិមនុស្ស[49] ដែលពិភាក្សា និងបកប្រែអំពីនិយាម និង កិច្ចធានា ។

## គ. ការធានាអំពីនីតិវិធីក្នុងការសម្រេចការឃុំខ្លួនបណ្តោះអាសន្ន

18. វិធាន ៦៣(១) គ្រប់គ្រងលើនីតិវិធីដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន:

> សហចៅក្រមស៊ើបអង្កេតអាចសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្តោះអាសន្ន ក្រោយពេលមានសវនាការតទល់គ្នា ។ ប្រសិនជនត្រូវចោទមិនទាន់មានជំនួយពីមេធាវីនៅឡើយទេ សហចៅក្រមស៊ើបអង្កេតត្រូវប្រាប់ជនត្រូវចោទ អំពីសិទ្ធិមានមេធាវីការពារ ដូចមានចែងនៅក្នុងវិធាន ២១-១(ឃ) ។ ជនត្រូវចោទមានសិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ ដើម្បីរៀបចំការការពារខ្លួន ។ ក្នុងពេលសវនាការតទល់គ្នានេះ សហចៅក្រមស៊ើបអង្កេតត្រូវស្តាប់សហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីជនត្រូវចោទ ។ នៅពេលបញ្ចប់សវនាការតទល់គ្នា សហចៅក្រមស៊ើបអង្កេតត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន [...] ប្រសិនបើសហចៅក្រមស៊ើបអង្កេតសម្រេចឃុំខ្លួនជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួន ។

---

[46] សូមអានមាត្រា ២៣នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក និងមាត្រា ១២(២)នៃកិច្ចព្រមព្រៀង និងវិធាន ២ ។

[47] សូមអានមាត្រា ៣៥ថ្មីនៃអ.វ.ត.ក ។

[48] ឧទាហរណ៍ តុលាព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ (the "ICC"), តុលាការព្រហ្មណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (the "ICTY"), តុលាការព្រហ្មទណ្ឌះអន្តរជាតិសំរាប់រវ៉ាន់ដា (the "ICTR") និងតុលាការពិសេសសៀរ៉ាឡេអូន (the "SCSL") ។

[49] ឧទាហរណ៍ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ និង តុលាការសិទ្ធិមនុស្សសហគមន៍អឺរ៉ុប (the "ECHR") ។

វិធាន ៦៣-១(ឃ) បានគូសបញ្ជាក់នូវសិទ្ធិបួនដាច់ៗពីគ្នា ប៉ុន្តែមានទំនាក់ទំនងជាមួយគ្នា មានជាអាទិ៍ សិទ្ធិទទួលបានសវនាការតទល់គ្នា[50], សិទ្ធិទទួលបានជំនួយពីមេធាវី, សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន និង សិទ្ធិចំពោះដីកាបង្គាប់ជាលាយលក្ខណ៍អក្សរ ។ ទោះបីជាចែងមិនច្បាស់ ការធានានូវដំណើរការនីតិវិធីបន្ថែមបានបញ្ចូលទៅក្នុងវិធាន ៦៣ តាមរយៈការយោងទៅវិធានដទៃទៀត ជាពិសេសសិទ្ធិនៅស្ងៀមមិនឆ្លើយតប[51] ។

## ១. ការលះបង់សិទ្ធិទទួលបានជំនួយពីមេធាវី

19. ដោយសារតែសវនាការនៅចំពោះមុខក.ស.ច.ស ពាក់ព័ន្ធជាសំខាន់ទៅនឹងការសួរចម្លើយជនត្រូវចោទ វិធាន ៦៣ត្រូវតែបានអានភ្ជាប់គ្នាជាមួយវិធាន ៥៨ មួយផ្នែកដូចខាងក្រោម:

> ២. ការសួរចម្លើយជនត្រូវចោទត្រូវតែធ្វើឡើងដោយមានវត្តមានរបស់មេធាវី លើកលែងតែជនត្រូវចោទយល់ព្រមឆ្លើយ ដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ខ្លួន និងត្រូវសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែក ដោយមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ ហើយដាក់ចូលទៅក្នុងសំណុំរឿង ។ ការយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវីរបស់ជនត្រូវចោទត្រូវថតទុក ដូចមានចែងនៅក្នុងវិធាន ២៥ [...]
>
> ៣. នៅក្នុងករណីបន្ទាន់ ដោយមានយល់ព្រមពីជនត្រូវចោទ សហចៅក្រមស៊ើបអង្កេតអាចសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់មានវត្តមានមេធាវី ។ ស្ថានភាពបន្ទាន់កើតឡើងនៅពេលណាដែលមានការជឿជាក់យ៉ាងច្បាស់ថា អាចបាត់បង់ជារៀងរហូត នូវភស្តុតាងនៅខណៈពេលរង់ចាំមេធាវីមកដល់ ដូចជាជនត្រូវចោទជិតដល់ពេលស្លាប់ជាដើម ។ មូលហេតុនៃស្ថានភាពបន្ទាន់នេះ ត្រូវសរសេរចូលឲ្យបានច្បាស់លាស់នៅក្នុងកំណត់ហេតុនៃការសួរយកចម្លើយ ។

---

[50] សូមអានវិធាន ២១(១)(ក) ("ដំណើរការនីតិវិធីក្នុងអ.វ.ត.ក ត្រូវមានយុត្តិធម៌ និងគោរពគោលការណ៍ចំពោះមុខហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ") ។

[51] សូមអានវិធាន ២១(១)(ឃ) ("ជនណាដែលត្រូវបានសង្ស័យ ឬត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេ មិនទាន់ត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធិទទួលបានដំណឹងអំពីបទចោទប្រកាន់មកលើខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសដោយខ្លួនឯង ហើយនិងនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី ត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប"), មាត្រ ៣៥ថ្មី នៃច្បាប់បង្កើតអ.វ.ត.ក ("នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា ១៤នៃអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ: [...] ឆ/ មិនត្រូវបានគេបង្ខំឲ្យធ្វើប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពកំហុស ។

20. វិធាន ៥៨(២) យោងទៅលើលទ្ធភាពនៃការយល់ព្រមឆ្លើយដោយមិនចាំបាច់មានវត្តមានមេធាវី ដំណើរការនីតិវិធីពិតប្រាកដប្រកបដោយភាពបត់បែន (ក្រៅពីតម្រូវការថា ការសួរចចម្លើយត្រូវសរសេរចូលក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរមួយដោយឡែក ដោយមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនត្រូវចោទ[52]) ក៏មិនបានបង្ហាញដែរ ។ ហេតុដូច្នេះ គេចាំបាច់ពិនិត្យបទដ្ឋានដែលបង្កើតនៅកម្រិតអន្តរជាតិ ដើម្បីដោះស្រាយភាពចន្លោះប្រហោងនេះ ។

21. អនុលោមទៅតាមនីតិវិធីព្រហ្មទណ្ឌដែលបង្កើតនៅកម្រិតអន្តរជាតិ ការលះបង់សិទ្ធិទទួលជំនួយពីមេធាវី ត្រូវតែបានកត់ត្រាទុកយ៉ាងត្រឹមត្រូវ[53] ។ ការយល់ព្រមឆ្លើយដោយអវត្តមានរបស់មេធាវីអាចត្រូវអនុញ្ញាត ប្រសិនបើធ្វើឡើងដោយស្មគ្រចិត្ត[54] ជូនដំណឹង[55]យ៉ាងច្បាស់[56] ។ សេចក្តីសំរេចមួយត្រូវតែពិចារណា

---

[52] សូមធ្វើការកត់សំគាល់ថា បន្ទាប់ពីបានពិនិត្យសំណុំរឿង មេធាវីការពារក្តីមិនបានប្រទះឃើញកំណត់ហេតុដោយឡែក ដែលតម្រូវដោយ វិធាន ៥៨(២)ទេ បើពិនិត្យទៅលើសវនាការតទល់គ្នា នៅពេលបង្ហាញខ្លួនលើកដំបូង ។

[53] វិធាននីតិវិធីរបស់ ICTY, ICTR, និង SCSL តម្រូវឲ្យមានការយល់ព្រមឆ្លើយផ្លូវការរបស់ជនសង្ស័យ ឬជនជាប់ចោទ ដែលនឹងត្រូវសួរចម្លើយដោយអាជ្ញាស៊ើបអង្កេត ដោយអវត្តមានរបស់មេធាវី ។ នៅពេលជនសង្ស័យ ឬជនជាប់ចោទយល់ព្រមឆ្លើយដោយអវត្តមានរបស់មេធាវី ការសួរយកចម្លើយត្រូវតែបញ្ឈប់ជាបន្ទាន់ នៅពេលជនសង្ស័យ ឬជនជាប់ចោទ បង្ហាញពីបំណងចង់បានជំនួយពីមេធាវី ហើយការយកចម្លើយនឹងមិនបន្តបានទេ ដរាបណាមានវត្តមានរបស់មេធាវី ។ សូមអានវិធាន ៤២(ខ) និង វិធាន ៦៣(ក) របស់ ICTY, ICTR, និង SCSL ។ លក្ខន្តិកៈ និង វិធានផ្ទៃក្នុងរបស់ ICC មានលក្ខណៈស្រដៀងគ្នានឹងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ។ សូមអានមាត្រា ៥៥(២)(ឃ)នៃលក្ខន្តិកៈ ICC និងវិធាន ១១២(១)(ខ) ។

[54] សូមពិនិត្យករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Delalic et al.*, សំណុំរឿងលេខ IT-96-21-T, សេចក្តីសំរេចលើពាក្យសុំទាត់ចោលភស្តុតាងរបស់ Zdravko Mucic ចុះថ្ងៃទី ២ ខែកញ្ញា ១៩៩៧ ("សេចក្តីសំរេចទាត់ចោលភស្តុតាងរបស់ *Delalic*") កថាខណ្ឌ ៤២ ។

[55] កំណត់ហេតុដែលទទួលបានក្រោមកាលៈទេសៈដែលអាជ្ញាធរស៊ើបអង្កេត បំភ័ន្តជនជនជាប់ចោទ និង/ឬខនខានស្រាយបំភ្លឺការភ័ន្តច្រឡំរបស់ជនជាប់ចោទ ភស្តុតាងបែបនេះនឹងទាត់ចោលនៅពេលសវនាការ ទោះបីជាជនជាប់ចោទចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ ដែលចង្អុលបង្ហាញថាគាត់បានអាន និងយល់ពីសិទ្ធិរបស់គាត់ក៏ដោយ។សូមពិនិត្យករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Bagosora et al.*, សំណុំរឿងលេខ ICTR-98-41-T សេចក្តីសំរេចពីសំណើរបស់ព្រះរាជអាជ្ញាសុំបញ្ចូលសម្ភារៈមួយចំនួន ក្រោមវិធាន ៨៩(គ) ចុះថ្ងៃទី ១៤ ខែតុលា ២០០៤ ("សេចក្តីសំរេចអំពីការបញ្ចូលរបស់ Bagosora") កថាខណ្ឌ ១០-២០ ។ វាបានឆ្លុះបញ្ចាំងគោលបំណងរបស់ប្រព័ន្ធច្បាប់ common-law ដែលតម្រូវឲ្យមានលះបង់សិទ្ធិជាមូលដ្ឋាន តែត្រូវធ្វើឡើងតាមស្ម័គចិត្ត ដឹងជាមុន និងដែលអានយល់បាន ។ មានន័យថា សាម៉ីជនត្រូវបានជូនដំណឹងយ៉ាងច្បាស់លាស់អំពីប្រភេទនៃសិទ្ធិ និងផលវិបាកដែលកើតចេញពីការលះបង់សិទ្ធិនេះ ។ សូមមើលករណី

ចរិតលក្ខណៈរបស់បុគ្គលដែលបានលះបង់សិទ្ធិ ព្រមទាំងរបៀបដែលសេចក្តីសំរេចត្រូវបង្កើតឡើង[57] នីតិវិធី ដែលមតិទូទៅយល់ថាសមស្រប ចំពោះមនុស្សពេញវ័យធម្មតា តែអាចត្រូវចាត់ថាមានលក្ខណៈគាបសង្កត់ នៅពេលអនុវត្តចំពោះកុមារ មនុស្សចាស់ជរា ឬបុគ្គលដែលមិនសាំជាមួយប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ[58] ។ ទស្សនទានអំពីការលះបង់សិទ្ធិដែលមានន័យមិនច្បាស់ គឺថាជនជាប់ចោទត្រូវអាចយល់ដឹងនូវសិទ្ធិដែលគាត់បានលះបង់ និងផលវិបាកជាក់ស្តែង បង្កឡើងពីការលះបង់សិទ្ធិនេះ ។ព័ត៌មាននេះ ត្រូវតែបានផ្តាស់ប្តូយ៉ាងទូលាំទូលាយ ហើយ"មិនត្រូវធ្វើឡើងតាមបែបរូបមន្តដែល[ជនត្រូវចោទ] មិនអាចយល់"[59] ។

---

*Miranda តទល់ជាមួយ រដ្ឋអារីហ្សូណា* តុលាការកំពូលសហរដ្ឋអាមេរិក 384 U.S. 346(1966), ទំព័រ ៤៧៥ ។ ករណី *R តទល់ជាមួយ Mortin* តុលាការកំពូលកាណាដា [1992] 1 SCR 771 ("ការលះបង់សិទ្ធិបែបនេះ ត្រូវតែប្រព្រឹត្តិឲ្យបានច្បាស់លាស់ ហើយសាម៉ីជនយល់ដឹងពីសិទ្ធិយ៉ាងពេញលេញ ហើយនីតិវិធីត្រូវបានអនុម័តដើម្បីការពារសិទ្ធិនេះ ហើយការលះបង់នឹងប៉ះពាល់ដល់សិទ្ធិទាំងនេះ") ។

[56] សូមអានសេចក្តីសំរេចបញ្ចូលរបស់ *Bagosoera* កថាខណ្ឌ ១៨ ។សូមអានករណី *Pfeifer និង Plankl តទល់ជាមួយ Australia,* ECHR ចុះនៅថ្ងៃទី ២៥ ខែកុម្ភះ ១៩៩២ កថាខណ្ឌ ៣៧ (អនុលោមទៅតាមយុត្តិសាស្ត្ររបស់ ECHR ("ការលះបង់សិទ្ធិដែលធានាដោយ[អនុសញ្ញាសហគមន៏អឺរ៉ុប]-មកដល់ពេលនេះមិនអានអនុញ្ញាតបានទេ-ត្រូវតែប្រព្រឹត្តទៅក្នុងលក្ខណៈច្បាស់លាស់ [...] ។ ប៉ុន្តែ ក្នុងករណីលះបង់សិទ្ធិខាងនីតិវិធី តម្រូវឲ្យមានការធានាអប្បបរមា ដើម្បីប្រសិទ្ធិភាពរបស់អនុសញ្ញា") ។

[57] សូមអានកថាខណ្ឌ ៦ នៃសេចក្តីសំរេចទាក់ទងទៅនឹងការទាត់ចោលរបស់ *Delalic* ។ សូមអានកថាខណ្ឌ ១៥ នៃសេចក្តីសំរេចទាក់ទងទៅនឹងការទទួលយករបស់ *Bagosora* (ការយល់ព្រមពិតប្រាកដត្រូវតែបានពិចារណា ក្នុងបរិបទនៃការសន្ទនាទាំស្រុង ដោយអមជាមួយនូវហត្ថលេខារបស់គាត់ផងដែរ") ។

[58] សូមអានកថាខណ្ឌ ៦៧នៃសេចក្តីសំរេចស្តីពីការទាត់ចោលរបស់ *Delalic* ។ សូមអានករណី *R តទល់ជាមួយ Evan* [1991] 1 SCR 869, ទំព័រ ៨៩០-៩១ ("ក្នុងករណីមានការចង្អុលបង្ហាញជាវិវត្តមានថា ជនជាប់ចោទមិនយល់ពីសិទ្ធិរបស់គាត់ក្នុងការទទួលបានជំនួយពីមេធាវី មន្ត្រីនគរបាលមិនអាចសំអាងលើការជូនដំណឹងរបស់ខ្លួន អំពីសិទ្ធិទៅឲ្យជនជាប់ចោទ ។ មន្ត្រីនគរបាលត្រូវតែចាត់វិធានការ ដើម្បីសំរួលដល់ការយល់អំពីសិទ្ធិនេះ [...] ។ មនុស្សម្នាក់ដែលមិន យល់ពីសិទ្ធិរបស់ខ្លួន នោះគេមិនអាចរំពឹងថា គាត់បានយល់ពីសិទ្ធិរបស់គាត់ឡើយ") (បញ្ជាក់បន្ថែម) ។

[59] សូមអានករណី *R តទល់ជាមួយ Cullen* ១៩៩២ NZLR LEXIS 689 (CA), ទំព័រ ១០ ("សិទ្ធិជាមូលដ្ឋានដែលមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្ស ១៩៩០ របស់ប្រទេស**ញូហ្សេឡែន** មិនត្រូវចាត់ទុកថាជារូបមន្ត ដែលជនជាប់ឃុំមិនអានយល់បានឡើយ ។ គោលបំណងដែលជំរុញឲ្យជនសង្ស័យយល់ដឹងអំពីសិទ្ធិរបស់គាត់ គឺថាគាត់អាចធ្វើសេចក្តីសំរេចថា តើថាគាត់ត្រូវប្រើសិទ្ធិទាំងនោះ ឬ មិនប្រើប្រាស់វា នៅពេលគាត់មិនយល់ថាសិទ្ធិទាំងនោះជាអ្វី") ។ សូមមើលករណី *S តទល់ជាមួយ Melani និង អ្នកដទៃទៀត* , 1995 SACLR LEXIS 290 ទំព័រ ៤៧-៤៨ (Sup. Ct.., Eastern Cape)

22. ជាអវសាន ជនម្នាក់ត្រូវតែមានសម្បទាខាងច្បាប់ក្នុងការលះបង់សិទ្ធិ[60] ។ ដំណើរការនីតិវិធីដ៏វែងបណ្តាលឲ្យស្ថានភាពផ្លូវកាយ និងបញ្ញាស្មារតីរបស់ជនត្រូវចោទចុះខ្សោយ ។ កត្តាទាំងនេះអាចធ្វើឲ្យសមត្ថភាពឆ្លើយសំណួរ និងពិគ្រោះយោបល់ជាមួយមេធាវីបាត់បង់- ស្ថានភាពបែបបង្កើតបានជាការបដិសេធនូវដំណើរការដោយយុត្តិធម៌ និងរំលោភបំពានគោលការណ៍សមភាពរវាងមេធាវីការពារក្តី និងព្រះរាជអាជ្ញា[61] ។ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា សម្បទារបស់ជនត្រូវចោទចុះអន់ថយ ដំណើរការនីតិវិធីត្រូវពន្យារពេល រហូតដល់គាត់មានសម្បទាល្អឡើងវិញ[62] ។

## ២. សិទ្ធិទទួលបានដីកាមានសំអាងហេតុ

23. វិធានតម្រូវឲ្យថា ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវតែមាន"សំអាងហេតុ"[63] និង"បញ្ជាក់ពីអង្គច្បាប់ និងអង្គហេតុដែលនាំឲ្យមានការឃុំខ្លួន"[64]។ លក្ខខណ្ឌតម្រូវទាំងនេះស្របតាមយុត្តិសាស្ត្រពាក់ព័ន្ធ ដែល

---

("ដើម្បីឲ្យសិទ្ធិរបស់ជនជាប់ចោទមានអានុភាព អនុលោមទៅតាមផ្នែក ២៥ (១)(គ) គាត់ត្រូវតែទទួលបានការជូនដំណឹងអំពីសិទ្ធិទទួលជំនួយពីមេធាវី ក្នុងមធ្យោបាយដែលគាត់អាចយល់អំពីខ្លឹមសារនៃសិទ្ធិទាំងនោះ") ។

[60] ទស្សនទាន "សម្បទាចូលរួមសវនាការ" យោងទៅលើកត្តានានាដែលអាចបង្កឲ្យចុងចោទគ្មានសម្បទាក្នុងការតវ៉ា, យល់ពីប្រភេទនៃការចោទប្រកាន់, យល់ពីដំណើរការនីតិវិធី, យល់ភស្តុតាងឲ្យបានស៊ីជំរៅ, ណែនាំមេធាវី, និងយល់ពីផលវិបាកដែលបង្កឡើងដោយដំណើរការនីតិវិធី ឬ ផ្តល់សក្ខីកម្ម-ដែលប៉ះពាល់ដល់ការចូលរួម ប្រកបដោយប្រសិទ្ធិភាពក្នុងដំណើរការនីតិវិធី របស់ជនជាប់ចោទ ។ សូមមើលករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Strugar* សំណុំរឿងលេខ IT-01-42-T, សេចក្តីសំរេចអំពីសំណើរបស់មេធាវីការពារក្តី ដើម្បីបញ្ឈប់ដំណើរការនីតិវិធី ចុះនៅថ្ងៃទី ២៦ ខែឧសភា ២០០៤ ("សេចក្តីសំរេចបញ្ឈប់ដំណើរការនីតិវិធីរបស់ Strugra" កថាខណ្ឌ ៣៦ ។

[61] ករណី *Barbera, Messegue និង Jabardo តទល់ជាមួយប្រទេសអេស្បាញ,* ECHR ចុះនៅថ្ងៃទី ៦ ខែធ្នូ ១៩៨៨ កថាខណ្ឌ ៧០ ។ ករណី *Makhfit តទល់ជាមួយបារាំង,* ECHR ចុះនៅថ្ងៃទី ១៩ ខែតុលា ២០០៤ កថាខណ្ឌ ៤០ ។ សូមអានករណី Stanford តទល់ជាមួយចក្រភពអង់គ្លេស, ECHR ចុះថ្ងៃទី ២៣ ខែកុម្ភះ ១៩៩៤ កថាខណ្ឌ ២៦ (សិទ្ធិរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការលើរឿងព្រហ្មទណ្ឌប្រកបដោយប្រសិទ្ធិភាព រួមបញ្ចូលទាំងសិទ្ធិមានវត្តនៅពេលសវនាការ និងទទួលបានជំនួយពីមេធាវី ព្រមទាំងសិទ្ធិទទួលបានការជូនដំណឹង និងតាមដានដំណើរការនីតិវិធី")។

[62] សូមមើលករណី S.C តទល់ជាមួយចក្រភពអង់គ្លេស, ECHR ចុះនៅថ្ងៃទី ១៥ ខែមិថុនា ២០០៤ កថាខណ្ឌ ២៣ ។ ករណី Stragar សេចក្តីសំរេចបញ្ឈប់, កថាខណ្ឌ២៧ ("តម្កល់គោលជំហររបស់ ECHR ដែលបានសំរេចថាករណីពុំមានសម្បទា នោះនឹងសាម៉ីជននឹងត្រូវទទួលការព្យាបាលរោគ ហើយសវនាការនឹងដំណើរការឡើងវិញ ពេលក្រោយ) ។

[63] វិធាន ៤៤(២)

[64] វិធាន ៦៣(២)(ក)

តម្រូវឱ្យមាន "ការយកចិត្តទុកដាក់ជាពិសេស" ក្នុងការវាយតំលៃ[65] ។ តុលាការប្រហែលជាមិនអាចគូសបញ្ជាក់ឱ្យបានលំអិត នូវគ្រប់ចំណុចនៃច្បាប់ទេ[66] ប៉ុន្តែសេចក្តីសន្និដ្ឋាន មានសារសំខាន់ដល់លទ្ធផលនៃរឿងក្តី ដែលត្រូវផ្តល់ការពន្យល់គ្រប់ជ្រុងជ្រោយ ។ មូលហេតុមានពីរ គឺ(១) អនុញ្ញាតឱ្យភាគីប្រើសិទ្ធិយ៉ាងប្រសិទ្ធិភាពដើម្បីប្តឹងជំទាស់ និង(២) រក្សានូវជំនឿទុកចិត្តរបស់សាធារណជននៅក្នុងរដ្ឋបាលយុត្តិធម៌[67] ។

## ឃ. លក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន

24. វិធាន ៦៣(៣) ផ្តល់មូលដ្ឋានរឹងមាំទាក់ទងទៅនឹងការចេញដីកាបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នរបស់ក.ស.ច.ស:

> សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ តែក្នុងលក្ខខណ្ឌដូចខាងក្រោម:
>
> (ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរបន្ថែម និង
>
> (ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការដ៏ចាំបាច់ដើម្បី:
>
> (១) រារាំងកុំឱ្យជនដែលត្រូវចោទគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ
>
> (២) ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង
>
> (៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី

---

[65] មាត្រ ៦នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សរបស់សគមន៍អឺរ៉ុប ដាក់កាតព្វកិច្ចដល់តុលាការជាតិ ដើម្បីបង្កើតសាលក្រមមានសំអាងហេតុ ។ សូមអានករណី *Bernard តទល់ជាមួយសាធារណរដ្ឋបារាំង*, ECHR ចុះនៅថ្ងៃទី ២៦ ខែកញ្ញា ២០០៧, កថាខណ្ឌ ៣៧ ។ ករណី *letellier តទល់ជាមួយសាធារណបារាំង*, ECHR ចុះនៅថ្ងៃទី២៦ ខែមិថុនា ១៩៩១ ។ ករណី *Hood តទល់ជាមួយចក្រភពអង់គ្លេស*, ECHR ចុះនៅថ្ងៃទី ១៨ ខែកុម្ភៈ ១៩៩៩ កថាខណ្ឌ ៦០ ។ ករណី *Smirnova តទល់ជាមួយប្រទេសរុស្ស៊ី*, ECHR ចុះនៅថ្ងៃទី ១៩ ខែតុលា ២០០៣, កថាខណ្ឌ ៧១ ។

[66] សូមមើលករណី *Van de Hurk តទល់ជាមួយប្រទេសហូឡង់*, ECHR ចុះនៅថ្ងៃទី១៩ ខែមេសា ១៩៩៤, កថាខណ្ឌ ៦១

[67] ករណី Vandjianastssiou តទល់ជាមួយប្រទេសអេស្បាញ, ECHR ចុះនៅថ្ងៃទី១៦ ខែធ្នូ ១៩៩២ កថាខណ្ឌ ៣៣

(៤) រក្សាសន្តិសុខឲ្យជនត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

តាមន័យនេះ វិធានបង្កើតនូវការសាកល្បងសំរាប់ដាក់លក្ខខណ្ឌឃុំខ្លួនបណ្តោះអាសន្ន ដែលតម្រូវឲ្យមានអត្ថិភាពនៃលក្ខខណ្ឌទាំងពីរ គឺ(១)មូលហេតុពិតប្រាកដគួរឲ្យជឿថា ជនត្រូវចោទបានចូលរួមក្នុងសកម្មភាពឧក្រិដ្ឋកម្ម[68] និង (២) លក្ខណៈវិនិច្ឆ័យបន្ថែមមួយបញ្ញត្តិនៅក្នុងវិធានៈ ៦៣(៣)(ខ) ។

25. អង្គជំនុំជម្រះនេះទាមទារនូវការសាកល្បងពីរជំណាក់កាលដែលបង្កើត គោលការណ៍នៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដែលផ្តល់នូវចរិតលក្ខណៈបទឧក្រិដ្ឋកម្មដែលចោទប្រកាន់ ពុំមានមូលដ្ឋានគ្រប់គ្រាន់ដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាជនត្រូវចោទ ត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរហើយភស្តុតាងប្រឆាំងគាត់ មានទំហំធ្ងន់ទៀតផង[69] ។ការអនុញ្ញាតឲ្យមានការឃុំខ្លួនបណ្តោះអាសន្នរយៈពេលវែង ដោយផ្អែកលើតែភាពធ្ងន់ធ្ងររបស់បទឧក្រិដ្ឋដែលចោទប្រកាន់ នឹងបង្កើតនូវរបបឃុំខ្លួនដែលចាប់បង្ខំក្នុងស្ថានភាពជាក់ស្តែង ដែលជាការរំលោភលើគោលការណ៍បង្កើតនៅកម្រិតអន្តរជាតិ ។

26. ពាក្យពេជន៏របស់វិធានផ្ទៃក្នុង-("សហចៅក្រមស៊ើបអង្កេតចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ តែក្នុងលក្ខខណ្ឌ[...][70]-គាំទ្រការអះអាងដែលថា ការឃុំខ្លួនបណ្តោះអាសន្នអនុវត្តចំពោះតែករណីពិសេស ជាជាងវិធានទូទៅ[71] ។ អង្គជំនុំជម្រះដែលត្រូវអាចវាស់វែងបានកំណត់នៅក្នុងវិធាន

---

[68] វត្តមាននៃការសង្ស័យសមហេតុផលដែលថា ជនត្រូវចោទមានប្រព្រឹត្តមួយ គឺជា"លក្ខខណ្ឌដាច់ខាត [sine qua non] សំរាប់ផ្តល់សុពលភាពការបន្តការឃុំខ្លួន" ករណី Letellier តទល់ជាមួយបារាំង, ECHR ចុះនៅថ្ងៃទី២៦ ខែមិថុនា ១៩៩១

[69] សូមមើលករណី *Letellier តទល់ជាមួយបារាំង*, ECHR ចុះនៅថ្ងៃ ២៦ ខែមិថុនា ១៩៩១ ។ ករណី *Ilijkov តទល់ជាមួយប្រទេសប៊ុលហ្គារី*, ECHR ចុះនៅថ្ងៃទី២៦ ខែកក្កដា ២០០១ នៅកថា ៨១ ។ សូមមើលករណី *ព្រះរាជអាជ្ញា តទល់ជាមួយ Haradinaj et al.*, សំណុំរឿងលេខ IT-04-84-PT, សេចក្តីសំរេចលើពាក្យសុំដោះលែងនៅក្រៅឃុំរបស់ Ramush Haradinaj, ចុះនៅថ្ងៃទី ៦ ខែមិថុនា ២០០៥ ("សេចក្តីសំរេចបង្គាប់ឲ្យដោះលែងនៅក្រៅឃុំ Haradinaj") កថាខណ្ឌ ២៤ ("មិនត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររយៈវែងទៅលើជនជាប់ចោទ ដោយពុំបានពិចារណាទៅលើអង្គហេតុនៅជុំវិញរឿងក្តី [*in abstracto*] ពីព្រោះជនជាប់ចោទទាំងអស់នៅចំពោះតុលាការ នឹងបញ្ឈរមុខនឹងការផ្តន្ទាទោសដាក់ក្នុងពន្ធនាគាររយៈពេលយូរ ប្រសិនបើតុលាការរកឃើញថាពួកគេមានកំហុស") (សម្រង់ពីយុត្តិសាស្ត្ររបស់ ICTY)

[70] វិធាន ៦៣(៣) (បញ្ជាក់បន្ថែម)

[71] សូមអានមាត្រា (៩)(៣)នៃ ICCPR, មាត្រានៃអនុសញ្ញាសហគមន៍អឺរ៉ុបសំរាប់ការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន, មាត្រា ៧នៃអនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិកាំង, មាត្រា ៦និង៧នៃធម្មនុញ្ញទ្វីបអាហ្វ្រិចស្តីពីសិទ្ធិមនុស្សរបស់ប្រជាជន, ដំណោះស្រាយលេខ ៤៣/១៧៣របស់មហាសន្និបាតនៃអង្គការសហប្រជាជាតិ, គោលការណ៍ ៣៩ នៃគោលការទូទៅដើម្បីការពារជនទាំងអស់ដែលស្ថិតនៅក្រោមការឃុំខ្លួនគ្រប់ទម្រង់ ។ សូមអានករណី *ព្រះរាជអាជ្ញាតទល់ជាមួយ*

00152325

៦៣(៣) គឺជាសេចក្តីត្រូវការដើម្បីធានាសេរីភាពបុគ្គល ដែលមិនត្រូវបានរំលោភបំពាន ដោយសារការព្រួយបារម្ភរបស់សាធារណ[72] ។ ទោះបីជាចែងមិនសូវច្បាស់ ក៏វិធាន ៦៣(៣) ត្រូវបានពង្រាងឡើងដោយគោរពគោលករណ៍សន្មតជាមុនថាទោស ដរាបណាពិរុទ្ធភាពមិនទាន់ត្រូវបានរកឃើញ[73] ។

27. ភាពប្រថុយប្រថានដែលថា ជនត្រូវចោទនឹងរត់គេច ត្រូវតែបានគាំទ្រដោយមូលដ្ឋានច្បាស់លាស់ ហើយមិនអាចវាយតំលៃដោយគ្រាន់តែ សំអាងលើភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋបានឡើយ[74] ។ ត្រូវតែមានសេចក្តីយោងចំពោះកត្តាជាក់លាក់ ដែលគាំទ្រ ឬបដិសេធភាពគ្រោះថ្នាក់[75] ។ សេចក្តីយោងទាំងនេះរួមបញ្ចូលទាំងចរិតលក្ខណៈ, ស្ថានភាពសុខភាព, ស្ថានភាពគ្រួសារ, សម្ភារៈ និង ធនធានហិរញ្ញវត្ថុរបស់ជនត្រូវចោទ ដែលមានទំទាក់ទំនងជាមួយយុត្តាធិការ[76] ។ ក្នុងករណីភាពប្រថុយប្រថាននឹងការ

---

*Hadzihasnovic និង Kubura*, IT-01-47-PT, សេចក្តីសំរេចបង្គាប់ឲ្យដោះលែង KUBURA នៅក្រៅឃុំ ចុះនៅថ្ងៃទី ១៩ ខែធ្នូ ២០០១("សេចក្តីសំរេចបង្គាប់ឲ្យដោះលែង *Hadzihasanovic* នៅក្រៅឃុំ") នៅកថាខណ្ឌ ៧ ("ការឃុំខ្លួនបណ្តោះអាសន្នត្រូវអនុវត្តក្នុងករណីពិសេស ហើយមិនត្រូវជាវិធានទាក់ទងទៅនឹងការចោទប្រកាន់នៅតុលាការអន្តរជាតិ)

[72] ដើម្បីធ្វើឲ្យមានតុល្យភាព "ផលប្រយោជន៍សាធារណពិតៗ" អាច "ធ្វើយុត្តិកម្មនឹងការចេញចេញពីវិធានគោរពសេរីភាពបុគ្គល" ។ ករណី *letellier តទល់ជាមួយបារាំង*, ECHR ចុះនៅថ្ងៃទី ២៦ ខែមិថុនា ១៩៩១ នៅកថាខណ្ឌ ៣៥ ។ សូមអាន ករណី *ព្រះរាជអាជ្ញាតទល់ជាមួយ Jokic* សំណុំរឿងលេខ IT-01-42/1-T ដីកាចុះថ្ងៃទី ២០ ខែកុម្ភៈ ២០០២ ("*Jokic* Order") (ក្នុងករណីអង្គជំនុំជម្រះពិចារណាលើសេចក្តីសំរេច ដោះលែងជនជាប់ចោទ ត្រូវតែពិចារណាអំពីតុល្យភាពរវាងប្រយោជន៍សាធារណ និង សិទ្ធិចំពោះសេរីភាពរបស់ជនជាប់ចោទ) កថាខណ្ឌ ១៩ (សម្រង់ចេញពីករណី Ilijkov តទល់ជាមួយប្រទេសប៊ុលហ្គារី, ECHR ចុះនៅថ្ងៃទី ២៦ ខែកក្កដា ២០០១ នៅកថាខណ្ឌ ៨៤) ។

[73] សូមអានវិធាន ២១(១)(ឃ) ។

[74] ករណី *Muller តទល់ជាមួយបារាំង,* ECHR ចុះនៅថ្ងៃទី ១៨ ខែកុម្ភះ ១៩៩៧, កថាខណ្ឌ ៤២ ។ ករណី *letellier តទល់ជាមួយបារាំង,* ECHR ចុះនៅថ្ងៃទី ២៦ ខែមិថុនា ១៩៩២ នៅកថាខណ្ឌ ៤៣ ។ ករណី *Neumeister តទល់ជាមួយប្រទេសអូទ្រីស*, ECHR ចុះនៅថ្ងៃទី ២៧ ខែមិថុនា ១៩៦៨ នៅកថាខណ្ឌ ១០ ។ ករណី *Tomasi តទល់ជាមួយបារាំង* ECHR ចុះនៅថ្ងៃទី ២៧ ខែសីហា ១៩៩២, នៅកថាខណ្ឌ ៩៨ ។ ករណី *Bernard តទល់ជាមួយបារាំង*, ECHR ចុះនៅថ្ងៃទី ២៦ ខែកញ្ញា ២០០៦ ។

[75] ករណី Yagci និង Sargin ទតល់ជាមួយប្រទេសទួរគី, ECHR ចុះនៅថ្ងៃទី ២៣ ខែឧសភា ១៩៩៥, កថាខណ្ឌ ៥៥

[76] ករណី *Neumeister តទល់ជាមួយប្រទេសអូទ្រីស*, ECHR ចុះនៅថ្ងៃទី ២៧ ខែមិថុនា ១៩៦៨ នៅកថាខណ្ឌ ១០ ។

រត់ជាមូលហេតុផ្លូវច្បាប់តែមួយគត់ ក្នុងការឃុំខ្លួនបណ្តោះអាសន្ន ជនត្រូវចោទត្រូវដោះលែងឱ្យនៅក្រៅឃុំរងចាំសវនាការ ប្រសិនបើមានធានាថា សាម៉ីជននឹងចូលខ្លួននៅពេលសវនាការ[77] ។

## ២. ការបំផ្លិចបំផ្លាញភស្តុតាង និង ការជ្រៀតជ្រែកទៅលើសាក្សី

28. ដូចបានជម្រាបពីខាងលើ ភាពប្រថុយប្រថានត្រូវតែផ្អែកទៅលើអង្គហេតុជាក់លាក់ និងភស្តុតាងដែលដាក់បន្ទុកមកលើជនត្រូវចោទ ហើយមិនគប្បីសំអាងទៅលើទស្សនទានអរូបីនៃស្ថានភាពបច្ចុប្បន្នឡើយ[78]។ ការអះអាងដោយគ្មានមូលដ្ឋាន ពឹងផ្អែកលើការប៉ាន់ស្មានទូទៅបែបនេះ ត្រូវតែបដិសេធចោល[79] ។ មូលហេតុដែលថា ជនត្រូវចោទនៅមានឥទ្ធិពល មិនមែនការចង្អុលបង្ហាញជាស្វយប្រវត្តិទេ "បើអញ្ចឹងមែន មានតែគាត់ប្រើឥទ្ធិពលខុសច្បាប់[80]

---

[77] ករណី Wemhoff តទល់ជាមួយប្រទេសអាល្លឺម៉ង់, ECHR ចុះនៅថ្ងៃទី ២៧ ខែមិថុនា ១៩៦៨ នៅកថាខណ្ឌ ១៥ ។ *letellier តទល់ជាមួយបារាំង,* ECHR ចុះនៅថ្ងៃទី ២៦ ខែមិថុនា ១៩៩១ នៅកថាខណ្ឌ ៤៦ ។ *Tomasi តទល់ជាមួយបារាំង* ECHR ចុះនៅថ្ងៃទី ២៧ ខែសីហា ១៩៩២, នៅកថាខណ្ឌ ៨៤ ។

[78] សេចក្តីសំរេចដោះលែង *Hardinaj* នៅកថាខណ្ឌ ២២ (ដោយយល់ឃើញថា "ការវាយតំលៃថាតើជនជាប់ចោទនឹងបង្កគ្រោះថ្នាក់ វាជាការយល់ឃើញដែលមានលក្ខណៈជាអរូបី តែភាពគ្រោះថ្នាក់ពិតប្រាកដត្រូវតែបានកំណត់" កថាខណ្ឌ ៤៧ និង៤៨ (ការរកឃើញ: ដោយសារតែ "មិនមានភស្តុតាងបញ្ជាក់ថា ជនជាប់ចោទបង្កភាពគ្រោះថ្នាក់ដល់នរណាម្នាក់រួមទាំងជនរងគ្រោះ និងសាក្សី អង្គជំនុំជម្រះរបស់សាលាដំបូងរកឃើញថា ពុំមានការលេចឡើងនូវការប៉ះពាល់ជាវិត្តមានទៅលើសុវត្ថិភាព របស់សាក្សីសក្តានុពល ដើម្បីធ្វើជាមូលដ្ឋានក្នុងការបដិសេធការដោះលែង ។ [...] ពុំមានភស្តុតាងអាចសន្និដ្ឋានបានថា ជនជាប់ចោទជ្រៀតជ្រែកទៅលើសាក្សី ឬនឹងជ្រៀតជ្រែកដំណើរការស្វែងរកយុត្តិធម៌") សូមពិនិត្យករណី *Labita តទល់ជាមួយប្រទេសអ៊ីតាលី,* ECHR ចុះនៅថ្ងៃទី ៦ ខែមេសា ២០០០, នៅកថាខណ្ឌ ១៦២-១៦៣ (ក្នុងករណីជនជាប់ចោទ ត្រូវឃុំខ្លួនរងចាំសវនាការអស់រយៈកាល ២ឆ្នាំ និង ៧ខែ ដោយមូលហេតុថា គាត់អាចគាបសង្កត់សាក្សី ឬបំផ្លាញភស្តុតាង ECHR កត់សំគាល់ឃើញថាមូលហេតុហ្នឹង មានលក្ខណៈទូទៅពេក: "អាជ្ញាធរ តុលាការអនុវត្តចំពោះអ្នកជាប់ឃុំទាំងអស់ជារួម ហើយគ្រាន់តែពិនិត្យប្រភេទបទល្មើសដែលដាក់បន្ទុកលើជនជាប់ចោទ ។ តុលាការមិនបានចង្អុលបង្ហាញកត្តាណាមួយ ដែលអាចគូសបញ្ជាក់អំពីអត្ថិភាពពិតប្រាកដនៃភាពប្រថុយប្រថាន ហើយខកខានក្នុងការបង្ហាញថា ជនជាប់ចោទបង្កភាពគ្រោះថ្នាក់" ។ តុលាការធ្វើសេចក្តីសន្និដ្ឋានថា "មូលហេតុចែងនៅក្នុងសេចក្តីសំរេច មិនមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើយុត្តិកម្មចំពោះការឃុំខ្លួនជនជាប់ចោទឡើយ" ។

[79] សេចក្តីសំរេចដោះលែង *Haradinaj* កថាខណ្ឌ ៤៤-៤៨

[80] សេចក្តីសំរេចដោះលែង *Haradinaj* នៅកថាខណ្ឌ ៤៧ (ករណី *ព្រះរាជអាជ្ញាតទល់ជាមួយ Prlic et al.,* សំណុំរឿង It-04-74-PT, ដីកាបង្គាប់ឱ្យដោះលែង Bruno Stojic, ចុះនៅថ្ងៃទី៣០ ខែកក្កដា ២០០៤ កថាខណ្ឌ ២៨) ។

29. សណ្តាប់ធ្នាប់សាធារណៈត្រូវបានទទួលស្គាល់ថា ជាយុត្តិកម្មបន្ថែមដែលត្រឹមត្រូវតាមច្បាប់មួយសម្រាប់ការឃុំខ្លួនជាបណ្តោះអាសន្ន[81]។ ទោះជាយ៉ាងណាក៏ដោយ ការគំរាមកំហែងជាអរូបិយ ទៅលើសណ្តាប់ធ្នាប់សាធារណៈ ដោយគ្រាន់តែផ្អែកលើភាពធ្ងន់ធ្ងរនៃបទល្មើសតែមួយគត់ មិនអាចត្រូវបានលើកមក ដើម្បីកាត់សេចក្តីលើការឃុំឃាំងបានឡើយ[82]។ អនុលោមទៅតាមសមាមាត្រភាពនៃគោលការណ៍ច្បាប់អន្តរជាតិ ការធ្វើយុត្តិកម្មលើដីកាឃុំខ្លួន ដោយសារមូលហេតុសណ្តាប់ធ្នាប់សាធារណៈ-ដូចមូលហេតុដទៃទៀតដែរ-អាចយកមកប្រើតែនៅពេលមានអង្គហេតុពិតប្រាកដ ដែលអាចធ្វើយុត្តិកម្មបាន ហើយដែលវាជាមធ្យោបាយតែមួយគត់ដែលអាចបំបាត់នូវភាពវឹកវរជាក់ស្តែងនេះ[83]។ អង្គភាពសិទ្ធិមនុស្សអន្តរជាតិសំដែងនូវការព្រួយបារម្ភចំពោះកាលដែលពឹងអាស្រ័យលើមូលហេតុសណ្តាប់ធ្នាប់សាធារណៈ ជាយុត្តិកម្មនៃការឃុំខ្លួនបណ្តោះ អាសន្ន ៖ "ទោះជាយ៉ាងណាក៏ដោយ សំណួរបានចោទឡើងថា ក្នុងសង្គមប្រជាធិបតេយ្យដែលគ្រប់គ្រងដោយវិធាននៃច្បាប់ ការឃុំខ្លួនបណ្តោះអាសន្ន ទោះបីជាក្នុងរយៈពេលខ្លីក៏ដោយ អាចត្រូវបានធ្វើយុត្តិកម្មស្របច្បាប់ ដោយសំអាង

---

[81] សូមមើលមាត្រា២០៥នៃCCCP ករណី *Letellier តទល់នឹងបារាំង* ECHR ២៦ មិថុនា ១៩៩១ កថាខ័ណ្ឌ៣៥ ករណី *Bernard តទល់នឹងបារាំង* ECHR ២៦ កញ្ញា ២០០៦ App. 27678/02។

[82] សូមមើលករណី *Bernard តទល់ជាមួយបារាំង* ECHR ២៦ កញ្ញា ២០០៦ កថាខ័ណ្ឌ៤៦ ករណី *Letellier តទល់ជាមួយបារាំង* ECHR ២៦ មិថុនា ១៩៩១ កថាខ័ណ្ឌ៥១ (ត្រង់កន្លែងដែលចៅក្រមបានថ្លែងថា បទល្មើសមួយចំនួនដោយសារភាពធ្ងន់ធ្ងរជាពិសេសណាមួយ និងប្រតិកម្មរបស់សាធារណជនទៅលើរឿងនេះ អាចបង្កឱ្យមានភាពចលាចលក្នុងសង្គម ដែលអាចធ្វើយុត្តិកម្មលើការឃុំខ្លួនជាបណ្តោះអាសន្ននេះ "យ៉ាងហោចណាស់សម្រាប់ពេលណាមួយ"។ ប៉ុន្តែចៅក្រមបានកត់សម្គាល់ដែរថា "មូលដ្ឋាននេះអាចលើកថា មានការពាក់ព័ន្ធ និងគ្រប់គ្រាន់ តែក្នុងករណីដែលបានបង្ហាញថាវាផ្អែកលើអង្គហេតុដែលអាចបង្ហាញថា ការដោះលែងជនជាប់ចោទអាចរំខានដល់សណ្តាប់ធ្នាប់សាធារណៈជាការពិត"។ ជាងនេះទៅទៀត តុលាការបានបង្ហាញថា "ការឃុំខ្លួននឹងនៅស្របច្បាប់ជាបន្តទៅទៀត តែក្នុងករណីដែលសណ្តាប់ធ្នាប់សាធារណៈនៅតែទទួលការគំរាមកំហែងយ៉ាងពិតប្រាកដដែល។ ការបន្តការឃុំខ្លួនមិនអាចត្រូវបានធ្វើឡើង ដើម្បីកាត់សេចក្តីលើការឃុំខ្លួននោះឡើយ")។ សូមមើលករណី *Kemmache តទល់ជាមួយបារាំង* ECHR ២7 វិច្ឆិកា ១៩៩១ កថាខ័ណ្ឌ៥២ ។ ករណី*ថូម៉ាស៊ី តទល់ជាមួយបារាំង* ECHR ២៧ សីហា ១៩៩២ កថាខ័ណ្ឌ៩១ ។ ករណី *I.A តទល់ជាមួយបារាំង* ECHR ២៣ កញ្ញា ១៩៩៨ កថាខ័ណ្ឌ១០៤។

[83] ដូចគ្នា។

00152328

លើសញ្ញាណនៃច្បាប់ដែលងាយនឹងរំលោភបំពានជាងសណ្តាប់ធ្នាប់សាធារណៈ[84]។ អាស្រ័យហេតុនេះ អាជ្ញាធរតុលាការគួរដោះស្រាយបណ្តឹងទាមទារទាំងនេះ ប្រកបដោយភាពប្រយ័ត្នប្រយែង ដើម្បីធានានូវអំពីវិធានការណ៍សមរម្យ ដោយការគោរពសិទ្ធិរបស់ជនត្រូវចោទ[85]។

## ង. ការដោះលែងដោយមានលក្ខណ្ឌ

30. វាជាអំណាចឆន្ទានុសិទ្ធិរបស់ក.ស.ច.ស ក្នុងការដោះលែងជាបណ្តោះអាសន្ន ដោយមានលក្ខណ្ឌសមរម្យ[86]។ នៅពេលធ្វើសេចក្តីសំរេចបែបនេះត្រូវអនុវត្តគោលការណ៍ទូទៅនៃសមាមាត្រភាព៖ លក្ខណ្ឌទាំងនេះ"គួរមិនផ្លាស់ប្តូរចុះឡើង ឬហួសហេតុ។ ប្រសិនបើវាមានលក្ខណៈគ្រប់គ្រាន់អនុវត្តវិធានការណ៍ទន់ភ្លន់ វិធានការណ៍ទន់ភ្លន់ត្រូវតែអនុវត្តបាន"[87]។ក្នុងបញ្ហាដទៃទៀត កត្តានានាដែលពាក់ព័ន្ធទៅនឹងការស៊ើបអង្កេត ដូចជាភាពធ្ងន់ធ្ងរនៃបទចោទប្រកាន់ សុខភាពជនត្រូវចោទ ការជិតមកដល់នៃការចាប់ផ្តើមសវនាការ ភាពទំនេរ និងប្រសិទ្ធិភាពនៃការត្រួតពិនិត្យរបស់ជនត្រូវចោទ ស្ថានភាព

---

[84] ការិយាល័យឧត្តមស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស *សិទ្ធិមនុស្សក្នុងរដ្ឋបាល យុត្តិធម៌៖ សៀវភៅអំពីសិទ្ធិមនុស្សសម្រាប់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ក្រុងញូវយ៉ក និងហ្សឺណែវ ២០០៣ ទំព័រ១៩៥*។

[85] គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានថ្លែងថា៖ "(...) ប្រសិនបើអះអាងថា ការឃុំខ្លួនជាការការពារសន្តិសុខសាធារណៈ ដូច្នេះវាក៏ត្រូវគ្រប់គ្រងដោយបញ្ញត្តិដូចនេះដែរ ឧទាហរណ៍ វាមិនត្រូវធ្វើឡើងតាមទំនើងចិត្ត ហើយការឃុំខ្លួនត្រូវមាន និងសមស្របតាមនីតិវិធីដែលបង្កើតដោយច្បាប់, ត្រូវប្រាប់មូលហេតុ ហើយតុលាការត្រូវគ្រប់គ្រងលើការឃុំខ្លួន ព្រមទាំងផ្តល់ជាសំណងជំងឺចិត្តក្នុងករណីរំលោភសិទ្ធិ។ ជាបន្ថែម ប្រសិនបើការចោទប្រកាន់ត្រូវបានសម្រេចក្នុងរឿងក្តីទាំងនេះ ការការពារយ៉ាងពេញលេញនៃមាត្រា ៩(២) និង(៣) និងមាត្រា១៤ ក៏ត្រូវបានធានាដែរ"។ សេចក្តីអធិប្បាយជាទូទៅ លេខ ៨ *ការចងក្រងសេចក្តីអធិប្បាយជាទូទៅអង្គការសហប្រជាជាតិ* ទំព័រ ១១៨។

[86] មាត្រា៥(៣) ECHRចែងថា៖ ជនណាម្នាក់ដែលត្រូវបានចាប់ខ្លួន ឬឃុំខ្លួន ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌ១(c) នៃមាត្រានេះ (...) ត្រូវទទួលបានការជំនុំជម្រះរយៈពេលសមស្រប ឬទទួលបានការដោះលែងដោយរង់ចាំការកាត់ក្តី។ ការដោះលែងអាចមានលក្ខណ្ឌដោយធានាថា នឹងបង្ហាញខ្លួននៅថ្ងៃសវនាការ"។

[87] សូមមើលសេចក្តីសម្រេចដោះលែងលោក *Hadzihasanovic* កថាខណ្ឌ៨ (វិធានការណ៍ក្នុងច្បាប់អន្តរជាតិសាធារណៈគឺសមាមាត្រតែនៅពេលដែលវាសមរម្យ សំខាន់ និងពេលដែលកម្រិត និងព្រំដែនរបស់វាស្ថិតនៅក្នុងទំនាក់ទំនងមួយដ៏សមហេតុផលទៅនឹងគោលបំណងដែលចង់បាន)។

ពេលចាប់ខ្លួនឬការប្រគល់ខ្លួនរបស់ជនត្រូវចោទ និងការធានាផ្សេងៗដែលបានផ្តល់ឲ្យ[88]។ ជាញឹកញយ តុលាការព្រហ្មទណ្ឌអន្តរជាតិជាច្រើនបានដោះលែងឲ្យនៅក្រៅឃុំ ចំពោះបទចោទប្រកាន់ធ្ងន់ធ្ងរ បើទោះបីជាដឹងយ៉ាងពេញលេញថា"នឹងពុំមានការធានាយ៉ាងដាច់ណាត់ថា ជនជាប់ចោទនឹងចូលខ្លួន នៅពេលសវនាការ ហើយប្រសិនបើត្រូវបានដោះលែង នឹងមិនបង្កគ្រោះថ្នាក់ដល់ប្រភពនៃភស្តុតាង"[89]។

---

[88] សូមមើលសេចក្តីសម្រេចដោះលែងលោក *Haradinaj* កថាខណ្ឌ២៣ (រាប់បញ្ចូលយុត្តិសាស្ត្រតុលាការICTY) ដីកាបង្គាប់ *Jokic* កថាខណ្ឌ១៩-២៥។

[89] សូមមើលសេចក្តីសម្រេចដោះលែងលោក *Hadzihasanovic* កថាខណ្ឌ៩ (នៅពេលដែលអង្គជំនុំជម្រះបានកំណត់ថា វាពុំចាំបាច់ទៀតទេនឹងអនុវត្តតាមដីកាបង្គាប់ឲ្យឃុំខ្លួន ដោយសម្អាងលើការយល់ព្រមប្រគល់ខ្លួនដោយស្ម័គ្រចិត្តរបស់ជនជាប់ចោទ គឺលោក *Hadzihasanovic* ការធានារបស់ជនជាប់ចោទ និងរដ្ឋាភិបាលប្រទេសបូស្នី និងអ៊ែរហ្សេហ្គូវីន និងលក្ខណ្ឌដែលបានតម្រូវ)។ សេចក្តីសម្រេចដោះលែងលោក *Haradinaj* កថាខណ្ឌ២៩-៤៨ (យល់ព្រមឲ្យដោះលែងបណ្តោះអាសន្នដោយមានដាក់ប្រាក់ធានា នៅពេលដែល៖ ជនជាប់ចោទត្រូវបានចោទពីបទល្មើសចំនួន៣៧ អំពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវប្រឈមមុខនឹងការដាក់ពន្ធនាគារក្នុងរយៈពេលយូរ។ សវនាការពុំត្រូវបានកំណត់ថាចាប់ផ្តើមក្នុងរយៈពេលយូរ ការប្រគល់ខ្លួនដោយស្ម័គ្រចិត្តរបស់ជនជាប់ចោទក្នុងលក្ខណៈជាគំរូមួយ ជនជាប់ចោទត្រូវបានគេស្គាល់ថាជាមនុស្សម្នាក់ដែលប្រកបដោយបូរណភាព ភាពថ្លៃថ្នូរ ចាស់ទុំ ទាំងផ្នែកនយោបាយ និងជាបុគ្គល ហើយមានចេតនាត្រលប់ចូលក្នុងសេវាសាធារណៈវិញ។ ជនជាប់ចោទបានប្រកាសថា នឹងអនុវត្តតាមរាល់ការបង្គាប់បញ្ជាទាំងអស់របស់តុលាការ UNMIKក៏បានផ្តល់ការធានា ហើយជនជាប់ចោទផ្ទាល់ក៏បានធានាថា ពុំមានទំនាក់ទំនង ឬលូកដៃ ដោយផ្ទាល់ ឬដោយប្រយោល ទៅលើសាក្សីសំខាន់ៗនោះឡើយ)។ ករណីព្រះរាជអាជ្ញា តទល់នឹង*Joseph Leki* សំណុំរឿងលេខ០៥/២០០០ ថ្ងៃទី២០ កុម្ភៈ ២០០០ (គណៈវិនិច្ឆ័យពិសេសសម្រាប់បទល្មើសធ្ងន់ធ្ងរនៅប្រទេសទីម័រខាងកើត ដែលបានសម្រេចកាលពីថ្ងៃទី២០ កុម្ភៈ ២០០១ ឲ្យដោះលែងជនជាប់ចោទ ដោយបានថ្លែងថា "ពុំមានមូលហេតុសមរម្យដែលអាចឲ្យជឿថា Joseph Leki ស្វែងរកការរត់គេចខ្លួនពីនីតិវិធីព្រហ្មទណ្ឌ" និង"មានមូលហេតុដើម្បីចេញវិធានការណ៍ជំនួស ជាការផ្លាស់គ្នាទៅនឹងដីកាសម្រេចឃុំខ្លួន ដើម្បីធានាលើបូរណភាពរបស់សាក្សី"។) *កំណត់សម្គាល់៖* នៅពេលដែលពាក្យសុំឲ្យមានការដាក់ត្រួតពិនិត្យតាមផ្លូវតុលាការ ពុំបានអនុញ្ញាតដោយតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដោយហេតុថាមានស្ថានការណ៍ពិសេសនៅប្រទេសសេរ៉ាឡេអូន (ដែលនៅទីនោះ)កត្តាប្រយោជន៍សាធារណៈ ដូចជា សមត្ថកិច្ចរបស់អាជ្ញាធរក្នុងការលើកឡើងនូវលក្ខណ្ឌ (...)មានលក្ខណៈប្រហាក់ប្រហែលច្រើន ប៉ុន្តែទទួលស្គាល់ថា នៅចំពោះមុខតុលាការពិសេស អាចមានកាលៈទេសៈណាមួយដែលជនជាប់ចោទអាចទទួលបានការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ៖ "ដោយហេតុថា ស្ថានភាព សុវត្ថិភាព និងរចនាសម្ព័ន្ធអាជ្ញាធរនៅប្រទេសសេរ៉ាឡេអូនវិវត្ត និងប្រសើឡើង កត្តាប្រយោជន៍សាធារណៈអាចពុំសូវមានទំងន់ធ្ងន់ក្នុងការថ្លឹងថ្លែងគ្នា"។ ករណី*ព្រះរាជអាជ្ញា តទល់នឹង Sesay et al.* សំណុំរឿងលេខ SCSL-04-15-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការដាក់ឲ្យស្ថិតក្រោមការត្រួត ពិនិត្យតាមផ្លូវតុលាការ ថ្ងៃទី១៤ ធ្នូ ២០០៤ កថាខណ្ឌ៣៦-៣៧។

00152330

ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវអនុវត្តតែក្នុងករណីពិសេស ជាជាងជាវិធានដែលមានលក្ខណៈដាច់ខាត នៅក្នុងករណីដែលជនត្រូវចោទ អាចបំពេញលក្ខណ្ឌនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដូចដែលបានសំរាលនៅក្នុងវិធាន៦៣(៣)(ខ) ដូច្នេះជាគោលការណ៏គាត់មានសិទ្ធិទទួលបានការដោះលែងឲ្យនៅក្រៅឃុំ[90]។

## V. អំណះអំណាង

### ក. សវនាការអំពីការឃុំខ្លួនបានប្រព្រឹត្តឡើងដោយរំលោភលើសិទ្ធិរបស់លោក នួន ជា

### ១. លោក នួន ជា ពុំបានបោះបង់សិទ្ធិទទួលជំនួយពីមេធាវីប្រកបដោយប្រសិទ្ធិភាព

31. ដោយពិនិត្យលើ(១) ស្ថានភាពផ្ទាល់ខ្លួនរបស់លោក **នួន ជា** (២) បរិបទអំពីការប្រព្រឹត្តទៅនៃសវនាការឃុំខ្លួន និង(៣) ផលវិបាកធ្ងន់ធ្ងរប្រកបដោយសក្តានុពល ដែលបណ្តាលមកពីការឃុំខ្លួនបណ្តោះអាសន្ន ក្នុងស្ថានការណ៍បែបនេះ នឹងពុំមានចៅក្រមប្រកបដោយសុភវិនិច្ឆ័យ អាចយល់ព្រមទទួលនូវការលះបង់របស់លោក **នួន ជា** នូវសិទ្ធិទទួលបានជំនួយពីមេធាវីឡើយ។ តាមពិត ចៅក្រមប្រកបដោយសុភវិនិច្ឆ័យ គប្បីទទួលស្គាល់ការលើកពេលសវនាការជាបន្ទាន់ និងក្នុងរយៈពេលខ្លី ដើម្បី អនុញ្ញាតឲ្យលោក *នួន ជា* សម្រាក និងស្តាប់នូវការប៉ឹក្សាយោបល់សមរម្យពីមេធាវីរបស់គាត់ ហើយគួរពិចារណានូវដំណើរការនីតិវិធីយ៉ាងណាដែលល្អបំផុត ។

32. ដូចដែលបានកត់សម្គាល់ពីខាងលើនេះ ដើម្បីឲ្យការលះបង់សិទ្ធិណាមួយមានសុពលភាពតាមច្បាប់ វាត្រូវតែធ្វើឡើងដោយស្ម័គ្រចិត្ត ទទួលការជូនដំណឹងយ៉ាងច្បាស់លាស់ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងស្ថានភាពទាំងនោះ ការលះបង់សិទ្ធិរបស់លោក **នួន ជា** នៅរសៀលថ្ងៃទី១៩ ខែកញ្ញា ២០០៧ គឺធ្វើឡើងតាមការបង្ខិតបង្ខំ ពុំបានទទួលការជូនដំណឹងជាមុន ហើយមិនច្បាស់លាស់។

---

[90] នៅខណៈដែលច្បាប់មនុស្សធម៌អន្តរជាតិមិនទទួលស្គាល់ "សិទ្ធិទទួលបានការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ" ថាជាសិទ្ធិដូច្នេះ វាពិតជាបានផ្តល់នូវ"*សិទ្ធិដាក់ពាក្យសុំ*ឲ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ ទៅតុលាការដែលបានបើកចំហ ដើម្បីធានាថា ការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទនោះគឺពុំចាំបាច់ធានានូវប្រសិទ្ធិភាពនៃការជម្រះក្តីឬសម្រាប់មូលហេតុប្រយោជន៍សាធារណៈមួយផ្សេងទៀត"។ ករណី*ព្រះរាជអាជ្ញា តទល់នឹង Norman et al.* សំណុំរឿងលេខ SCSL-04-14-A សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៏របស់Fofana ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ថ្ងៃទី១១ មិនា ២០០៥ កថាខណ្ឌ៣២។

### ក. ការលះបង់សិទ្ធិ ធ្វើឡើងដោយគ្មានការស្ម័គ្រចិត្ត

33. លោក **នួន ជា** ត្រូវបានចាប់ខ្លួននៅព្រឹកព្រលឹមថ្ងៃទី១៩ កញ្ញា ២០០៧ ដោយនគរបាលយុត្តិធម៌របស់ អ.វ.ត.ក នៅផ្ទះរបស់គាត់នៅក្រុងប៉ៃលិន។ បន្ទាប់មក គាត់ត្រូវបាននាំខ្លួនតាមឧទ្ធម្ភាគចក្រឆ្ពោះមកក្រុងភ្នំពេញ ហើយនាំខ្លួនបន្តតាមរថយន្តមកកាន់អគារអ.វ.ត.ក ហើយតម្រូវឲ្យដើរទៅកាន់អគារតុលាការ ជាទីកន្លែងដែលគាត់បានជួបក្នុងរយៈពេលយ៉ាងខ្លី ជាមួយមន្ត្រី អ.គ.ក.ក មុននឹងចូលបង្ហាញខ្លួនជាលើកដំបូងនៅម៉ោង២និង៤០នាទីរសៀល។ ក្នុងខណៈដែលព្រឹត្តិការណ៍ដែលកើតឡើងជាបន្តបន្ទាប់នេះ អាចជាមិនសាកសម្បអនុវត្តលើមនុស្សវ័យកណ្តាលដែលមានសុខភាពល្អ តែលោក **នួន ជា** ដែលមានអាយុ៨២ឆ្នាំ ដើរដោយកាន់ឈើច្រត់ និងឈឺចាប់ដោយសារជំងឺលើសឈាមរ៉ាំរ៉ៃ និងជំងឺបេះដូង-សសៃឈាមរបស់គាត់[91]។ សវនាការអំពីការឃុំខ្លួនបានចាប់ផ្តើមនៅម៉ោង៤និង២៥នាទីរសៀល លោក **នួន ជា** បានអត់ធន់នឹងលក្ខណ្ឌ និងថ្ងៃដែលគួរឲ្យថប់អារម្មណ៍និងដែលលំបាកសម្រាប់មនុស្សវ័យស្របាលគាត់។ សមត្ថភាពរបស់គាត់ ក្នុងការគិតគូរឲ្យបានច្បាស់លាស់នៅក្នុងថ្ងៃសវនាការអំពីការឃុំខ្លួន-ចំពោះនីតិវិធីដែលគាត់ពុំធ្លាប់ដែលបានជួបប្រទេះ ឬយល់ដឹងទាល់តែសោះ-ត្រូវបានចុះអន់ថយយ៉ាងពិតប្រាកដ ដែលមានន័យថា គាត់ពុំសមនឹងទៅជជែកការពារក្តីបានឡើយ។ ដូច្នេះ ការលះបង់ចោលនូវសិទ្ធិនោះ ត្រូវតែបានបកស្រាយថា បានធ្វើឡើងដោយមានការបង្ខិតបង្ខំ ។

### ខ. ការបោះបង់ចោលនូវសិទ្ធិពុំត្រូវបានជូនដំនឹងឡើយ

34. ក្នុងអម្លុងពេលនៃសវនាការអំពីការឃុំខ្លួននោះ លោក **នួន ជា** ពុំត្រូវបានជូនដំណឹងអំពីផលវិបាកដែលបង្កឡើងដោយដំណើរការនីតិវិធី ប្រសិនបើគ្មានជំនួយពីមេធាវីការពារក្តី ។ ឧទាហរណ៍ គាត់ពុំបានទទួលបានការជូនដំណឹងអំពីការឃុំខ្លួនបណ្តោះអាសន្ន ដែលគ្រប់គ្រងដោយក្រមនីតិវិធីដ៏ស្មុគស្មាញព្រមទាំងយុត្តិសាស្ត្រអន្តរជាតិដ៏ធំទូលាយ ហើយថា ក.ស.ព អាចដាក់សេចក្តីសន្និដ្ឋានលើអង្គហេតុ និងអង្គច្បាប់ដែលលោក **នួន ជា** អាចឆ្លើយតបវិញ ។ គាត់ក៏ពុំត្រូវបានជូនដំណឹងថា ចម្លើយរបស់គាត់នៅក្នុងសវនាការ អាចយកធ្វើជាផ្នែកមួយនៃសំណុំរឿងរបស់គាត់ និងក្រោយមកទៀតវាអាចត្រូវប្រើប្រឆាំងទៅលើគាត់វិញ- ដោយសារតែបញ្ហានេះ-គាត់មានសិទ្ធិនៅស្ងៀមពុំឆ្លើយតបនៅក្នុងសវនាការ ។ ជាងនេះទៅទៀត ពុំមានការពន្យល់ថា សវនាការអាចត្រូវបានពន្យាររហូតដល់លោក

[91] គេបានប្រមាណឃើញថាលោក នួន ជា

**សុន អរុណ** មកដល់ ឬថាក្នុងអម្លុងពេលនោះ លោក **នួន ជា** អាចស្នើសុំឲ្យមានមន្ត្រីរបស់ អ.គ.ក.ក ជួយគាត់ ។

35. បន្ថែមពីលើនេះ ហាក់ដូចជាពុំមានភាពច្បាស់លាស់ថា តើលោក **នួន ជា** ត្រូវបានផ្តល់ប្រឹក្សាថា សិទ្ធិទទួលបានជំនួយពីមេធាវី-ដែលគាត់ត្រូវបានជូនដំណឹងនៅពេលបង្ហាញខ្លួនលើកដំបូង-ត្រូវបានពង្រីក និងអនុវត្តស្មើគ្នានៅពេលធ្វើសវនាការអំពីការឃុំខ្លួន ។ តាមពិត ក.ស.ព បានសំដែងពីការព្រួយបារម្ភទាក់ទងទៅនឹងការលះបង់សិទ្ធិ ដោយទទូចសុំចៅក្រម ធ្វើការពន្យល់លោក **នួន ជា** អំពីសិទ្ធិរបស់គាត់ឲ្យបានច្បាស់ធ្វើដូច្នេះ គាត់អាចយល់កាន់តែ "ច្បាស់លាស់"អំពីសិទ្ធិទាំងនេះ[92] ។ ប៉ុន្តែ លោកចៅក្រម **យូ ប៊ុនឡេង** គ្រាន់តែយោងទៅលើ"ទំរង់"ដែលបានអាន នៅពេលបង្ហាញខ្លួនជាលើកដំបូងតែប៉ុណ្ណោះ ហើយជាចុងក្រោយសវនាការបានប្រព្រឹត្តឡើងដោយពុំមានផ្តល់ការបំភ្លឺតាមសំណើសុំរបស់ ក.ស.ព ឡើយ ។

36. តាមពិត មានការពន្យល់បន្តិចបន្តួចដល់លោក **នួន ជា** នៅក្នុងសវនាការអំពីការឃុំខ្លួន ហើយភាពស្រេកឃ្លានដែលអាចមើលឃើញយ៉ាងច្បាស់របស់ចៅក្រម នៅក្នុងការរៀបចំសវនាការឲ្យបានលឿនបំផុត ដែលអាចធ្វើទៅបាន បានធ្វើឲ្យលោក **នួន ជា** យល់ឃើញថាគាត់មានជម្រើសបន្តិចបន្តួចតែប៉ុណ្ណោះ ប៉ុន្តែត្រូវតែបន្តនីតិវិធីទៅមុខ ដោយពុំចាំបាច់ជំនួយពីមេធាវីរបស់គាត់ ។ បើទោះជា មិនមែនជាមុខងាររបស់សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់នូវដំបូន្មានផ្នែកច្បាប់ទៅជនត្រូវចោទ ប៉ុន្តែពួកគេមានភារៈធានាថា លោក **នួន ជា** បានយល់ដឹងអំពីសិទ្ធិជាមូលដ្ឋានរបស់គាត់ និងផលវិបាកពីការលះបង់សិទ្ធិនេះ ។ ដោយហេតុថា ក.ស.ច.ស ខកខានចំពោះភារកិច្ចនេះ ដូច្នេះ ការលះបង់សិទ្ធិនេះពុំត្រូវបានជូនដំណឹងឡើយ។

## គ. ការលះបង់សិទ្ធិមានភាពមិនច្បាស់លាស់

37. ដូចដែលបានកត់សម្គាល់ដោយ ក.ស.ព លោក **នួន ជា** "ជាដំបូងបានសំណូមពរឲ្យមានមេធាវី ក្រោយមកគាត់បាននិយាយថា ពុំចាំបាច់មានមេធាវីសម្រាប់សវនាការនេះទេ"[93]ការអធិប្បាយជាបន្ត

[92] របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ក.ស.ច.ស (ឯកសារលេខ C-8) ទំព័រ២-៣ (ការគូសបញ្ជាក់បន្ថែម)។

[93] របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ក.ស.ច.ស (ឯកសារលេខ C-8) ទំព័រ២-៣ (ការគូសបញ្ជាក់បន្ថែម)។

បន្ទាប់របស់លោក **នួន ជា** ដែលថាគាត់ចង់ឲ្យបន្តនីតិវិធីដោយពុំចាំបាច់មានលោក **សុន អរុណ** ត្រូវបានលើកឡើងយ៉ាងជាក់ស្តែងដោយចៅក្រម ជាការបំភ្លឺលើរឿងក្តីនេះ។ ទោះយ៉ាងណាក៏ដោយ ក្នុងកាលៈទេសៈដូចដែលបានរៀបរាប់ខាងលើនេះ វាស្រដៀងដូចគ្នាដែលថា លោក **នួន ជា** បានលំឱន កាយចំពោះការកៀបសង្កត់នៅខាងក្នុង ក្នុងការបន្តនីតិវិធីសវនាការ។ ដោយហេតុថា ក.ស.ច.ស ពុំបាននិយាយពាក្យពាំត្រណោតជាមួយនឹងការបំភ្លឺនោះ-ប៉ុន្តែជាជាងនិយាយដដែលឡើងវិញក្នុងភាសាដូចគ្នា នូវអ្វីដែលបាននិយាយរួចហើយ-វាពុំច្បាស់លាស់ដែលថា ការយល់ច្រលំយ៉ាងជាក់ស្តែងរបស់លោក **នួន ជា** ត្រូវបានកែប្រែ។ អាស្រ័យហេតុនេះ យើងមិនអាចនិយាយបានថា ការលះបង់សិទ្ធិនេះមានភាពមិនច្បាស់លាស់ ។

**២. ដូច្នេះ សវនាការអំពីការឃុំខ្លួននេះគ្មានយុត្តិធម៌**

38. ការបដិសេធសិទ្ធិមានមេធាវីរបស់លោក **នួន ជា**-ឧទាហរណ៍ ការយល់ព្រមទទួលការលះបង់សិទ្ធិដែលប្រកបដោយវិការៈនោះ-ត្រូវបូកបញ្ចូលជាមួយការបដិសេធសិទ្ធិបន្ថែម និងជាមូលដ្ឋានដែលធានាដោយវិធានផ្ទៃក្នុង ជាពិសេសសិទ្ធិរបស់លោក **នួន ជា** ទទួលបានសវនាការតទល់គ្នា, សិទ្ធិទទួលបានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំការការពារខ្លួន, សិទ្ធិនៅស្ងៀមមិនឆ្លើយ និងសមភាពរវាងព្រះរាជអាជ្ញា និងមេធាវី ។

39. ដូចដែលបានសង្ខេបពីខាងលើនេះ លោក **នួន ជា** ត្រូវបាននាំខ្លួនតាមឧទ្ធម្ភាគចក្រពីផ្ទះរបស់គាត់ដែលធ្វើពីឈើយ៉ាងសាមញ្ញនៅក្រុងប៉ៃលិន មកកាន់ទីកន្លែងយ៉ាងទំនើបរបស់ អ.វ.ត.ក ដែលស្ថិតក្នុងទីក្រុង ដែលនៅទីនោះហើយ ពេលមកដល់ភ្លាម រូបគាត់ត្រូវបានរំពឹងទុកថា នឹងត្រូវចូលរួមក្នុងនីតិវិធីព្រហ្មទណ្ឌអន្តរជាតិមួយដែលគាត់ពុំដែលស្គាល់សោះ។ ដោយអស់កម្លាំងពីថ្ងៃធ្វើការ និងពុំមានជំនួយពីមេធាវីរបស់គាត់ ឬតំណាងរបស់ អ.គ.ក.ក គាត់ត្រូវបានបង្ខំឲ្យទទួលយកសវនាការដ៏សំខាន់និងស្មុគស្មាញមួយ ដោយពុំបានទទួលនូវការពន្យល់អំពីអង្គហេតុ ឬអង្គច្បាប់ណាមួយ ឬក៏ការជូនដំណឹងឲ្យបានច្បាស់លាស់អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយឡើយ ។ គូបដិបក្ស របស់គាត់នៅក្នុងសវនាការអំពីការឃុំខ្លួននោះមាន សហព្រះរាជអាជ្ញាទាំងពីរ និងបុគ្គលិករបស់ពួកគេជាបន្ថែមទៀត-សុទ្ធសឹងជាមេធាវីដែលមានបទពិសោធន៍ និងមានចំណេះដឹងខាងច្បាប់ ដែលត្រូវយកមកអនុវត្ត និងអង្គហេតុនៃរឿងក្តី។ នៅពេលដែលលោក **នួន ជា** ព្យាយាមតបទៅលើសេចក្តីសន្និដ្ឋានរបស់ក.ស.ព

វិញនោះ។ តាមរយៈរបាយការណ៍ វាបានបង្ហាញយ៉ាងច្បាស់ថា គាត់ពុំមានលទ្ធភាពអាចចូលរួមបានយ៉ាងត្រឹមត្រូវឡើយ។ ពេលនោះ វាបានបង្ហាញយ៉ាងច្បាស់ថាគាត់ពុំអាចការពារខ្លួនគាត់បានទេ។

40. តាមច្បាប់ ទស្សនទាននៃសវនាការតទល់គ្នាចង្អុលប្រាប់នូវចំនួនជាអប្បរមានូវភាពស្មើគ្នារវាងភាគីទាំងសងខាង ដែលបានឆ្លុះត្រលប់មកវិញពីគោលការណ៍សមភាពរវាង ព្រះរាជអាជ្ញា និងមេធាវី។ ទោះជាយ៉ាងណាក៏ដោយ ការដែលពណ៌នាអំពីនីតិវិធីដែលបានប្រព្រឹត្តកាលពីថ្ងៃទី១៩ កញ្ញា ២០០៧ ថាជា"ការតទល់គ្នា" គឺជាការដែលធ្វើឱ្យអត្ថន័យនៃពាក្យនោះទៅជាគ្មានន័យ ។

## ខ. លក្ខណ្ឌដើម្បីឃុំខ្លួនជាបណ្តោះអាសន្នពុំត្រូវបានបំពេញឡើយ

### *១. ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីចងភ្ជាប់លោក នួន ជា ទៅនឹងបទឧក្រិដ្ឋដែលបានចោទ*

41. វិធាន ៦៣(៣)(ក) បានតម្រូវឱ្យមាន "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម"។ ក.ស.ច.ស បានរកឃើញថា ខ្នែងដំបូងនៃការសាកល្បងត្រូវបានបំពេញ ដោយសារ"ឯកសារ និងចម្លើយសាក្សីជាច្រើនដែលដាក់បន្ទុកលើ **នួន ជា**" បានភ្ជាប់មកជាមួយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ ក.ស.ព[94]។

42. សម្រាប់លោក **នួន ជា** វិញគាត់នៅតែអះអាងអំពីនិរទោសនៃបទចោទមកលើរូបគាត់ ហើយបានបដិសេធជាសាធារណៈ រាល់ការចូលរួមក្នុងសកម្មភាពឧក្រិដ្ឋទាំងឡាយ[95]។ មេធាវីការពារក្តីសន្និដ្ឋានថាទោះបីជាចំនួនឯកសារជាច្រើនបានដាក់ដោយ ក.ស.ពដែលឯកសារទាំងនោះបានដាក់បន្ទុកលោក **នួន ជា** គឺជាឯកសារដែលត្រូវបានស្ទេន និងរួមបញ្ចូលស្ទើរតែទាំងស្រុងនូវពាក្យបញ្ចិតបញ្ចៀងផ្ទាល់ខ្លួនបន្តិចបន្តួចនិងអាគតដ្ឋានមិនពិតប្រាកដ។ នៅខណៈពេលដែលមេធាវីការពារក្តីមិនប្រកែកថាឈ្មោះលោក **នួន ជា** មាននៅក្នុងឯកសារជាច្រើន ប៉ុន្តែប្រសិនបើមានតំលៃនៃនីតិបច្ចេកវិទ្យាបានភ្ជាប់ទៅឯកសារយោងនោះ។ តាមពិតវាពុំមានការបញ្ជាក់ច្បាស់លាស់ពីក្នុងរបាយការណ៍អំពីសវនាការឃុំខ្លួន ឬក៏ដីកាសម្រេចឃុំខ្លួនថា ក.ស.ច.ស បានធ្វើអ្វីផ្សេងបន្ថែមក្រៅតែអំពីការពិនិត្យមើលយ៉ាងប្រញាប់ប្រញាល់នូវសំណុំរឿងតែប៉ុណ្ណោះ។

---

[94] ដីកាសម្រេចឃុំខ្លួន កថាខ័ណ្ឌ ៥។

[95] ឯកសារលេខ C-8 របាយការណ៍ជាលាយល័ក្ខអក្សរអំពីសវនាការតទល់គ្នា ទំព័រ៤។

00152335

43. ក្នុងស្ថានការណ៍ណាមួយ វាពុំមែនយល់ព្រមលើភាពសមហេតុផលនៃការរកឃើញរបស់ ក.ស.ច.ស ចំពោះបញ្ហានេះឡើយ ប៉ុន្តែសន្មតថាបានរកឃើញមូលហេតុគួរឱ្យជឿបានថា លោក **នួន ជា** បានប្រព្រឹត្តបទល្មើស ដោយផ្អែកលើជំហរតែមួយនេះ គឺវាពុំគ្រប់គ្រាន់ដើម្បីគាំទ្រលើដីកាសម្រេចឃុំខ្លួនជាបណ្តោះអាសន្ននោះឡើយ។

## ២. ពុំមានទឡ្ហីករណ៍បន្ថែមដើម្បីធ្វើយុត្តិកម្មលើការឃុំខ្លួនបណ្តោះអាសន្ន

44. ដូចដែលតម្រូវដោយវិធាននិងគោលការណ៍នៃនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ ក.ស.ច.ស បានធ្វើយុត្តិកម្មបន្ថែមលើដីការឃុំខ្លួនបណ្តោះអាសន្ន ដោយយោងទៅលើភាពគ្រោះថ្នាក់គ្មានមូលដ្ឋាន ៖ ហានិយភ័យនៃការរត់គេចខ្លួន **នួន ជា** ពីដំណើរការនីតិវិធី ការគ្រៀកគ្រៀងទៅលើសាក្សីសក្តានុពល ជាពិសេសអ្នកដែលសង្ស័យថាស្ថិតនៅក្រោមការត្រួតត្រារបស់គាត់កាលពីមុន និងលទ្ធភាពនៃគំរាមកំហែងសណ្តាប់ធ្នាប់សាធារណៈ និង សន្តិសុខផ្ទាល់របស់ **នួន ជា** ។ ទោះយ៉ាងនេះក្តី ការធ្វើយុត្តិកម្មទាំងនេះគឺផ្អែកតែទៅលើសញ្ញាណអរូបី ជាជាងទឡ្ហីករណ៍នៅក្នុងអង្គហេតុពិតប្រាកដ ។

### ក. ពុំមានហានិយភ័យពិតប្រាកដនៃការរត់គេចខ្លួនរបស់ **នួន ជា** ពីដំណើរការនីតិវិធី

45. តែមួយគត់ដែលបង្ហាញនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងស៊ើបសួររបស់ ក.ស.ព. លើចំណុះនេះគឺថា **នួន ជា** កាន់លិខិតឆ្លងដែន និងរស់នៅជិតព្រំប្រទល់ប្រទេសថៃ[96]។ចំពោះ **នួន ជា** វិញគាត់បានបង្ហាញថា បើគាត់មានបំណងរត់គេចខ្លួនោះ គាត់បានរត់បាត់ខ្លួនទៅហើយ និង គាត់មានបំណងចូលរួមក្នុងដំណើរការនីតិវិធី[97] បើទោះជាគាត់បានមានឱកាសជាច្រើននឹងធ្វើដូច្នោះក៏ដោយ ។ ក.ស.ច.ស លើកឡើងថា”ពីព្រោះ **នួន ជា** ប្រឈមមុខនិងការដាក់ទោសអតិបរិមាដោយជាប់ពន្ធនាគារមួយជីវិត បើរកឃើញថាមានទោស ចំណុចនេះធ្វើឱ្យមានការខ្លាចថា **នួន ជា** នឹងរត់គេចខ្លួនពីដំណើរការនីតិវិធី បើទោះបី **នួន ជា** ប្រកែកចំពោះការលើកឡើងនោះក៏ ដោយ[98]។

---

[96] ដូចគ្នា ទំព័រ៣

[97] ដូចគ្នា ទំព័រ៣.៤

[98] ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ៥

46. ផ្អែកតាមអង្គហេតុ សញ្ញាណនៃការរត់គេចខ្លួនរបស់ **នួន ជា** ពីដំណើរការនីតិវិធី អ.វ.ត.ក ជាហេតុមិនអាចឲ្យជឿបាន។តាមពិត **នួន ជា** បាននិយាយជាច្រើនដង ជាពិសេសនៅសវនាការអំពីការឃុំខ្លួនបណ្ដោះអាសន្នតថា គាត់មានបំណងចូលរួមក្នុងដំណើរការនីតិវិធីយ៉ាងខ្លាំង[99]។ គាត់ជាប្រជាពលរដ្ឋខ្មែរម្នាក់ដែលពេញចិត្តនឹងខ្លួនឯងនិងជាមួយគ្រួសារ និង មានបំណងជាពលរដ្ឋស៊ីវិលចំពោះប្រទេសជាតិ ហើយគ្មានបំណងរត់ចោលអ្នកទាំងនោះឡើយ។ **នួន ជា** បានដឹងយ៉ាងច្បាស់ថា ការនាំខ្លួនដែលនឹងកើតមានចំពោះរូបគាត់និងការបន្តស៊ើបអង្កេតនិងគ្មានចេតនាប៉ុនប៉ងរត់គេចពីលំនៅរបស់គាត់នៅប៉ៃលិនឡើយ។ ជាការពិតដោយមាន អ្នកសារពត៌មានផងដែរនោះ គាត់បានរង់ចាំទាំងអំណត់នូវការមកដល់នៃអាជ្ញាធរ អ.វ.ត.ក នៅព្រឹកនៃថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ បើទោះបីជាការបង្ហាញកំលាំងក្នុងការអនុវត្តដីកានាំខ្លួនក៏ **នួន ជា** ស្ម័គ្រចិត្តប្រគល់ខ្លួនភ្លាម និង គ្មានការរារែកចំពោះដីកានោះដែរ។ជាទឡ្ហីករណ៍ បើទោះជាសន្មត់ថា លោក **នួន** ជាមានបំណងរត់គេចខ្លួន ជរាភាពរបស់គាត់រួមមាន អាយុ សុខភាព និង ការខ្វះធនធានហិរញ្ញវត្ថុ[100]ធ្វើឲ្យគាត់គ្មានលទ្ធភាពធ្វើដូច្នោះបានឡើយ។ អាជ្ញាធរកម្ពុជា និង អ.វ.ត.ក មានប្រាកដណាស់នូវឆន្ទះ និង លទ្ធភាពខាងសំភារៈគ្រប់គ្រាន់ដើម្បីឃ្លាំមើល កំរិតកំណត់សកម្មភាពរបស់ **នួន ជា** នៅក្នុងស្រុកបានយ៉ាងប្រាកដ។

47. គ្មានការប៉ុនប៉ងណាមួយត្រូវបានលើកឡើងនៅឯសវនាការស្ដីអំពីឃុំខ្លួន ដើម្បីទទួលបាននូវការធានានៃការចូលខ្លួនពីអ្នកធានាឬការធានាណាមួយឬពី **នួន ជា** (ទោះបីជាគាត់បានផ្ដល់ការធានាមួយដោយគ្មាន លក្ខខ័ណ្ឌហើយក៏ដោយ) ហើយក៏គ្មានសេចក្ដីយោងណាបានលើកឡើងក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចំពោះកត្តាជាក់លាក់នានាដែលតម្រូវ ដែលអាចគាំទ្រ ឬ ទាត់ចោលហានិភ័យនៃការរត់គេចខ្លួនពីដំណើរការ នីតិវិធី។ ដូចបានរៀបរាប់ពីកថាខ័ណ្ឌមុនៗមកហើយ តុល្យការបានគាំទ្រយ៉ាងធ្ងន់ដល់ការគ្មានហានិភ័យ។និយាយសរុបមក គឺគ្មានហានិភ័យនៃការរត់គេចខ្លួនពីដំណើរការនីតិវិធីឡើយ។ ខ្លឹមសារនៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នថែងយ៉ាងច្បាស់ថា ក.ស.ច.ស បាន

---

[99] សូមមើល ៥ អនុកថាខ័ណ្ឌ

[100] ផ្នែកគាំពារការពារក្ដីបានកំណត់ថាលោក នួន ជា មិនមានធ្យោបាយដើម្បីចំណាយលើការពារក្ដីរបស់គាត់។ ចូរមើលឯកសារ លេខក.៤៩ លិខិតរបស់ផ្នែកគាំពារការពារក្ដីអំពីការកំណត់អំពីមធ្យោបាយ ចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៧។



ꝺov

ផ្អែកការវាយតំលៃរបស់ខ្លួនតែទៅលើទម្ងន់នៃការចោទប្រកាន់ប្រឆាំង **លោក នួន ជា** ។ ដូចបានអះអាងពីខាងលើមកហើយ នេះជាការសន្មត់មិនអាចទទួលយកបានតាមគតិយុត្តិ។

## ខ. ពុំមានហានិភ័យជាក់ស្តែងដែលនាំឲ្យ **នួន ជា** ចូលជ្រៀតជ្រែកសាក្សី

48. ដើម្បីគាំទ្រចំណុចនេះ ក.ស.ព សន្និដ្ឋានថា **នួន ជា** ពីមុនធ្លាប់បានស្តីបន្ទោសអ្នកក្រោមបង្គាប់របស់គាត់ ថាមិនបានបំផ្លាញភស្តុតាងចោល[101]។ ជាចម្លើយតប **នួន ជា** បាននិយាយថា គាត់គ្មានលទ្ធភាពបំផ្លាញភស្តុតាងចោលបានទេ[102]។ក.ស.ច.ស គូសបញ្ជាក់ថា "ដោយពិចារណាពីតំណែងតាមឋានានុក្រមរបស់ **នួន ជា** (បងធំទី២នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ) បើសិនទុកឲ្យគាត់នៅមានសេរីភាពនោះ ខ្លាចក្រែងគាត់នឹងប៉ុងប៉ងគាបសង្កត់ សាក្សី និង ជនរងគ្រោះជាពិសេសអ្នកធ្លាប់នៅក្រោមអំណាចរបស់គាត់[103]។

49. ហានិភ័យនៃការរត់គេចខ្លួន គ្រោះថ្នាក់បង្កឡើងដោយការគាបសង្កត់សាក្សី និងឬ ការបំផ្លាញភស្តុតាងត្រូវបានគាំទ្រដោយ អង្គហេតុជាក់លាក់ទាក់ទិនជាមួយជនត្រូវចោទ ។ ទោះយ៉ាងណាក្តី ការចោទប្រកាន់របស់ ក.ស.ព ទៅលើការរិះគន់របស់ **នួន ជា** កាលពីពេលមុន គឺការចោទប្រកាន់គ្មានមូលដ្ឋានក្រៅតែពីការធ្វើអធិប្បាយមិនមាំទាំប៉ុណ្ណោះ ។ ដូចគ្នានេះដែរ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នខ្វះអង្គហេតុគាំទ្រ ហើយជំនួសវិញដោយការអធិប្បាយបែបសន្មត់ដូចជា "ខ្លាចក្រែង" គាត់ប្រហែលប៉ុនប៉ង" គាត់នឹងមានជំហរអាចគាបសង្កត់ សាក្សី និង ជនរងគ្រោះ"[104]។ ដោយផ្អែកលើកំណត់ហេតុសព្វថ្ងៃ នេះជាការសន្មត់មិនសមហេតុផល និង មិនអាចអនុវត្តបានតាមគតិយុត្តិ ដូច្នេះត្រូវតែបដិសេធចោល។ដូចបានរៀបរាប់ពីខាងលើមក ជាក់ស្តែងបើទោះជា **នួន ជា** ទំនងជាអាចនៅមានវិធានការមានឥទ្ធពលមួយចំនួន ក៏មិនមានន័យថា នឹងអនុវត្តឥទ្ធពលនោះដោយខុសច្បាប់ឡើយ ។ នៅក្នុងកំណត់ ហេតុក៏គ្មានភស្តុតាងទាល់តែសោះដែលថា **នួន ជា** បានធ្វើការទាក់ទងដោយមិន

---

[101] ឯកសារ លេខ គ៨ កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ទំព័រ ៣

[102] ដូចគ្នា ទំព័រ ៤

[103] ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ៥

[104] ដូចគ្នា ទំព័រ ៤

ត្រូវតែបដិសេធចោល។ដូចបានរៀបរាប់ពីខាងលើមក ជាក់ស្តែងបើទោះជា **នួន ជា** ទំនងជាអាចនៅមានវិធានការមានឥទ្ធពលមួយចំនួន ក៏មិនមានន័យថា នឹងអនុវត្តឥទ្ធពលនោះដោយខុសច្បាប់ឡើយ ។ នៅក្នុងកំណត់ ហេតុក៏គ្មានភស្តុតាងទល់តែសោះដែលថា **នួន ជា** បានធ្វើការទាក់ទងដោយមិនសមរម្យជាមួយសាក្សី ជនរងគ្រោះ ឬ ភាគីទីបីណាម្នាក់ ឬ ថាបានលើកទឹកចិត្តតាមវិធីផ្សេងៗ ឱបំផ្លាញឯកសារទាំងឡាយទាក់ទិន ជាមួយករណីប្រឆាំងគាត់[105]។

គ. គ្មានការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ ឬ សន្តិសុខ **នួន ជា** ផ្ទាល់ខ្លួន

50. ការិយាល័យអយ្យការ គ្មានអង្គហេតុគាំទ្រទឡ្ហីករណ៍ទាំងនេះទេ ហើយ **នួន ជា** បានថ្លែងជំទាស់ថា (១) គាត់បានចុះចូលនិងចូលរួបរួមក្នុងសង្គមកម្ពុជាដោយសន្តិភាពរួចមក[106]ហើយ(២) បើនរណាមួយប្រាថ្នាធ្វើឃាតខ្ញុំ គេអាចធ្វើបាន[107]។ ទោះយ៉ាងណាក្តី ចំណុចដែល ក.ស.ច.ស បានលើកឡើងថាពីព្រោះទម្ងន់នៃបទឧក្រិដ្ឋ និង បទឧក្រិដ្ឋដែល **នួន ជា** បានត្រូវចោទ តម្រូវឲ្យមានការឃុំខ្លួនបណ្តោះអាសន្ន[108]។ ជំហរនេះ មិនអាចអនុវត្តបានតាមគតិយុត្តិ និង ជាអង្គហេតុមិនសុចរិត។

51. ដោយមកពីផ្អែកតែទៅលើទម្ងន់នៃបទឧក្រិដ្ឋដែលបានចោទ ដើម្បីធ្វើយុត្តកម្មមូលហេតុទាំងនោះ ហើយ ក.ស.ច.ស បានបំពានលើការអនុវត្តន៍ដែលបានហាមហាត់ ដូចដែលបានលើកឡើងពីខាងលើ។ ទាក់ទិននិងចំណុចនេះ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទំនងជាបានចេញ ដោយរំពឹងទុកជាមុនឱមានការឃុំខ្លួនដ៏វែងមួយ ហើយ យល់ថា ក.ស.ច.ស ទំនងជាបានសេចក្តីវិនិច្ឆ័យជាមុនលើបញ្ហាពិរុទ្ធភាពរបស់ **នួន ជា** ។ ផ្អែកតាមគោលការណ៍ទទួលស្គាល់ជាអន្តរជាតិ ការឃុំខ្លួនបណ្តោះអាសន្ន ផ្អែកលើការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណ នឹងអាចមានយុត្តិកម្មបានល្គឹកណាតែមានការបង្ហាញនូវអង្គហេតុជាក់លាក់នៃការរំខានណាមួយ និង ល្គឹកណាតែការឃុំខ្លួននោះ

---

[105] ជាបន្ថែមទៀត ការគិតគូរបស់ការិយាល័យអយ្យការចំពោះករណីនេះ ត្រូវតែពិនិត្យមើលយោងតាមអង្គហេតុ ដែលចោទថាបានប្រព្រឹតបទឧក្រិដ្ឋអស់ជាង៣០ឆ្នាំមកហើយ។ជាទឡ្ហីករណ៍ បើទោះជាសន្មត់ថា លោក **នួន** ជាមានបំណងកែប្រែកំណត់ហេតុប្រវត្តិសាស្រ្ត បើមិនឥតលទ្ធភាព ចំណុចនេះ ទំនងយ៉ាងខ្លាំងថាគាត់អាចទទួលជោគជ័យ ដោយហេតុថារាល់សកម្មភាពរបស់ខ្មែរក្រហមត្រូវបានចងជាឯកសារ និងកត់ត្រាយ៉ាងល្អរួចហើយ។

[106] ឯកសារ លេខ គ៨ កំណត់ហេតុនៃកិច្ចពិភាក្សាជេញជោល ទំព័រ ៣

[107] ដូចគ្នា ទំព័រ ៤

[108] ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ៥

52. ដូចដែលបានរៀបរាប់រួចមកហើយ **នួន ជា** បាននិងកំពុងរស់នៅជាចំហនិងសុខសាន្តនៅ ប៉ៃលិនអស់ពេលច្រើនឆ្នាំហើយ ដែលជារយៈពេលគ្មានអំពើហិង្សាប្រឆាំងនឹងសេរីភាពរបស់គាត់ ឬ អំពើប៉ុនប៉ងសងសឹកគាត់ឡើយ។ ជាក់ស្តែង មានមុខសញ្ញារបស់ អវតក ដែលគេដឹងឮគ្រប់គ្នាថាកំពុងរស់នៅក្នុងប្រទេសកម្ពុជានោះ ទំនងជាមិនបានធ្វើអ្វីឲរំខានសណ្តាប់ធ្នាប់សាធារណៈទេ។ ទឡ្ហីករណ៍ដែលបានលើកឡើងថាសង្គមកម្ពុជានឹងពិបាកយល់ និង ឆ្លើយតបដោយត្រឹមត្រូវចំពោះគំនិតអំពីការដោះលែងនួនជាបណ្តោះអសន្ន ជាទឡ្ហីករណ៍មិនត្រឹមត្រូវ និង គំនិតនេះមិនត្រូវបានយកចិត្តទុកដាក់អស់ពេលជាង១០ឆ្នាំនៃប្រវត្តិសាស្ត្រកម្ពុជារួចមកហើយដែរ។ ដូចដែល **នួន ជា** បានថ្លែងក្នុងសវនាការស្តីអំពីការឃុំខ្លួនបណ្តោះអាសន្នថា "ខ្ញុំបានចេញពីក្នុងព្រៃពីខ្ញុំបានយល់ពីបន្ទាត់នយោបាយនៃរដ្ឋាភិបាលដឹកនាំដោយនាយករដ្ឋមន្ត្រី **សម្តេចហ៊ុន សែន** ជាពិសេស នយោបាយចូលរួបរួមក្នុងសង្គមជាតិឡើងវិញ[109]។ ជាការពិតណាស់ ការអធិប្បាយនេះសំដៅលើគោលនយោបាយដ៏ប្រជាប្រិយ៍របស់រដ្ឋាភិបាលដែលបានចាប់ផ្តើមនៅដើមឆ្នាំ១៩៩៤ និងដែលបានបញ្ចូលអតីតសមាជិកខ្មែរក្រហមមករស់នៅក្នុងសង្គមជាតិវិញ[110]។ **នួន ជា** បានចាប់ផ្តើមចុះចូលនិងរួមរស់ជាមួយសង្គមជាតិវិញជាផ្លូវការតាមសំណើសុំជាផ្លូវការទៅ **សម្តេច ហ៊ុន សែន** នៅខែធ្នូ ឆ្នាំ១៩៩៨[111] និងរួមទាំង **ខៀវ សំផន** ផងត្រូវបានស្វាគមន៏ឲចូលមករស់ក្នុងសង្គមវិញដោយនាយករដ្ឋមន្ត្រី[112]។

53. យោបល់បន្ថែមទៀត ដែលឲឃុំខ្លួន **នួន ជា** បណ្តោះអាសន្ននឹងទុបស្កាត់រាល់ការតវ៉ាអំពីការឈឺចិត្តក៏ចោទជាបញ្ហាដែរ។ ការសម្តែងមតិជាសាធារណៈនៃការមិនសុខចិត្តចំពោះអំពើរបស់មន្ត្រី ត្រូវតែលើកទឹកចិត្តឲ្យធ្វើក្នុងសង្គមចំហ បើការសម្តែងមតិនោះ គ្មានបង្ហាញអំពីហិង្សា។ពាក់ព័ន្ធជាមួយការយកចិត្តទុកដាក់របស់ អវតក អំពីការបញ្ជូនសារទៅសាធារណជន នេះជាករណីមួយ ត្រូវគោរពតាមគោលការណ៏គតិយុត្តិដែលមានស្រេច ហើយមិនត្រូវផ្អែកលើ ការប៉ាន់ស្មានមិនត្រឹមត្រូវលើស្ថាន

---

[109] ឯកសារ លេខ គ៨ កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ទំព័រ ៣

[110] ចូរមើល ដូចជា ស៊ូហ្សានាហ លិនតុន ការផ្សះផ្សាជាតិក្នុងប្រទេសកម្ពុជា(មជ្ឈមណ្ឌលឯកសារកម្ពុជា២០០៤)ទំព័រ ៨១។

[111] ចូរមើល របាយណ៏សាពត៏មាន ប៊ីប៊ីស៊ី ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ១៩៩៨។ http:news.bbc.co.uk/2hi/asia-pacific/242670.stm

[112] ដូចគ្នា "ខ្ញុំសូមសំដែងការស្វាគមន៏យ៉ាងកក់ក្តៅចំពោះអ្នកទាំងពីរដែលបានចូលមករួមរស់ក្នុងសង្គមជាតិនិងបាទទួលស្គាល់រដ្ឋធម្មនុញ្ញកម្ពុជា"។

ភាពសន្តិសុខ ដែលលាបពណ៌ប្រជាពលរដ្ឋថា ជាហ្វូងមនុស្សឥតសណ្តាប់ធ្នាប់ និងធ្វើអ្វីៗតាមអារម្មណ៍ ។

### ៣. ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នមិនបានសម្រេចទៅតាមបុព្វហេតុអង្គហេតុ

54. ដូចដែលបានរៀបរាប់ពីខាងលើមកហើយ គ្មានមូលហេតុណាមួយនៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន មានអង្គហេតុគ្រប់គ្រាន់តម្រូវឲមានតាម វិធាន៦៣(២)(ក)។ ទាំង ក.ស.ច.ស និង ក.ស.ព បានប្រព្រឹត្តិហួសការអធិប្បាយនៃលក្ខខណ្ឌតម្រូវ នៃវិធាន(៦៣)។ នេះមិនគ្រាន់ តែធ្វើឲលំបាកដល់មេធាវិការពារក្តីក្នុងការដាក់បណ្តឹងឧទ្ធរណ៍ឲបានសមរម្យប៉ុណ្ណោះទេ ថែមទាំងបន្សល់ទុកនូវខ្លឹមសារចម្លែកដែលថាការឃុំខ្លួន **នួន ជា** បណ្តោះអាសន្នជាសេចក្តីសម្រេច កែប្រែមិនបាន និង រួមជាមួយការខ្លាចក្រែងយ៉ាងពិតប្រាកដថានឹងផ្តល់ផលជាអវិជ្ជមានដល់ជំនឿរបស់សាធារណជនចំពោះដំណើការនីតិវិធីផងដែរ។

### គ. ការដោះលែងបណ្តោះអាសន្នជាការត្រឹមត្រូវតាមសភាពការនេះ

55. ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ក.ស.ច.ស បានធ្វើការសន្និដ្ឋានថា“មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណះតឹងរឹង និង មានប្រសិទ្ធភាព អាចធានាអោយមានការបំពេញកិច្ចការប្រកបដោយប្រសិទ្ធិភាព ចំពោះស្ថានភាពតម្រូវទាំងអស់នេះទេ (វិធាន៦៣(៣)(ខ) ហើយ ថាការឃុំខ្លួននៅតែជាមធ្យោបាយតែមួយគត់ដើម្បីសម្រេចគោលដៅខាងលើនេះ[113]។ ទោះយ៉ាងណាក្តី យោងតាមសភាពជាក់ស្តែងនៃកិច្ចការដូចបានរៀបរាប់ខាងលើនេះ បង្ហាញអោយឃើញថាការប៉ាន់ស្មាននេះហួសហេតុ និង នៅមានការសង្ស័យ។

56. នៅឯសវនាការអំពីការឃុំខ្លួន ការិយាល័យសហចៅក្រមស៊ើបអង្កេតខកមិនបានរុករក ឬ បានពិចារណារកវាល់វិធានការធូរស្រាលអនុលោមតាមគោលការណ៍សមាមាត្រឡើយ ដូចជាការដោះលែង

---

[113] 113 ដីកាសម្រេចអោយឃុំខ្លួនបណ្តោះអាសន្ន កថាខ័ណ្ឌ៦

បណ្តោះអាសន្នស្ថិតនៅក្រោមលក្ខខ័ណ្ឌសមស្រប។ ជាពិសេស ការិយាល័យសហចៅក្រមស៊ើបអង្កេតខកមិនបានពិចារណាលើ អាយុ និង សុខភាពរបស់ **នួន ជា** សភាពការណ៏នៃការចាប់ខ្លួននិងការចុះចូល កិច្ចធានាដោយ **នួន ជា** ខ្លួនឯង លទ្ធភាពនៃការធានាបន្ថែមធ្វើដោយភាគីជាអ្នកធានាពេលវេលាជិតមកដល់នៃការជំនុំជម្រះ និង ប្រសិទ្ធិភាពនិងលទ្ធភាពនៃការឃ្លាំមើលធ្វើឡើងដោយអាជ្ញាធរ។

57. កត្តានីមួយជំរុញអោយមានការដោះលែងជាបណ្តោះអាសន្ន។ ដូចបានរៀបរាប់លំអិតរួចមកហើយ អាយុនិង សុខភាពរបស់ **នួន ជា** មិនធ្វើអោយគាត់ដើរហើរវែងឆ្ងាយពីផ្ទះរបស់គាត់បានទេ។ ស្ថានភាពនៃការចាប់ខ្លួនរបស់គាត់បញ្ជាក់ថាគាត់ពិតជាចង់ចូលរួមក្នុងដំណើរការនីតិវិធី និង ស្ម័គ្រចិត្តចូលខ្លួន បើសិនជាស្នើសុំ។ ពិតណាស់ គាត់បានធ្វើការធានាចំពោះវត្តមានផ្ទាល់ខ្លួន និង ស្ម័គ្រចិត្តរកកិច្ចធានាថែមទៀត បើសិនតម្រូវ ។ បន្តមកទៀត ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញយ៉ាងច្បាស់អំពីបំណងធ្វើរឿងក្តី **កាំង ហ្កេចអ៊ាវ** អោយបានលឿន នេះបង្ហាញអោយឃើញថា ការជំនុំជម្រះ **នួន ជា** ទំនងនឹងមិនធ្វើឆាប់ៗនោះទេ[114]។ ជាចុងបញ្ចប់ និង ករណីទំនងគួរអោយជឿបានបំផុតគឺ ឆន្ទះដែលបានបង្ហាញ និង លទ្ធភាពខាងអាជ្ញាធរកម្ពុជាក្នុងការបែងចែកកំលាំង និង ចាប់ខ្លួនជនដែលបានសង្ស័យថាបានប្រព្រឹត្តិឧក្រិដ្ឋកម្ម[115]។ មានហេតុផលជាក់លាក់អោយជឿបានថាអាជ្ញាធរទាំងនោះ មានលទ្ធភាពខ្ពស់នឹងធ្វើកិច្ចការឃ្លាំមើល និង ចាប់ខ្លួនបុរសជរាភាពដូចជា **នួន ជា** សារជាថ្មី បើចាំបាច់។

58. ផ្អែកលើលក្ខខ័ណ្ឌបានស្នើដែលចែងក្នុងឧបសម្ព័ន្ធ ក គ្មានអង្កេសចក្តីអរូបីណាមួយ ដែលបានលើកឡើងដោយ ក.ស.ព អាចយកធ្វើជាមូលហេតុធ្ងន់ធ្ងរអោយទៅជាអង្គហេតុជាក់ស្តែងបានទេ។

---

[114] ចូរមើលឯកសារលេខ ឃ១៧ ដីកាបញ្ជូនរឿងទៅពិនិត្យដើម្បីបំបែកសំណុំរឿងរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៨ កញ្ញាឆ្នាំ ២០០៧ ទំព័រ២ (" យើងត្រូវមានដំណោះស្រាយមួយបានលឿនចំពោះករណី ឌុច ដោយហេតុថាជននេះត្រូវបានឃុំខ្លួនបណ្តោះអាសន្ននៅក្នុងក្របខ័ណ្ឌនីតិវិធីផ្សេងៗអស់ រយះពេល ៨ ឆ្នាំមកហើយ ដូចដែលមានរៀបរាប់នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី ៣១ កក្កដា ២០០៧។ម្យ៉ាងវិញទៀត ការបើកសវនាការជាសាធារណះ នៅក្នុងរយះពេលឆាប់ៗមានសារះសំខាន់ជាសារវ័ន្ត ដល់ភាពដែលអាចជឿជាក់បានរបស់តុលាការដោយពិនិត្យមើលលើអតីតភាពនៃអង្គេហេតុរឿងក្តីនេះ"។

[115]អាជ្ញាធរកម្ពុជាពីអតីតកាលបានចាប់អតីតមេដឹកនាំខ្មែរក្រហម និង មន្ត្រីរាជការជាន់ខ្ពស់នានា ដូចជាអតីតអភិបាលក្រុងភ្នំពេញជាដើម។

00152342

ធរទាំងនោះ មានលទ្ធភាពខ្ពស់នឹងធ្វើកិច្ចការឃ្លាំមើល និង ចាប់ខ្លួន បុរសជរាភាពដូចជា **នួន ជា** សារជាថ្មី បើចាំបាច់។

58. ផ្អែកលើលក្ខខ័ណ្ឌបានស្នើដែលចែងក្នុងឧបសម្ព័ន្ធ ក គ្មានអង្គេសចក្តីអរូបីណាមួយ ដែលបានលើកឡើងដោយ ក.ស.ព អាចយកធ្វើជាមូលហេតុធ្ងន់ល្មមអោយទៅជាអង្គហេតុជាក់ស្តែងបានទេ។ ការអនុវត្តវិធានការធូរស្រាលទាំងនេះ នឹងធ្វើអោយ **នួន ជា** រឹតតែឯកកោពីជនត្រូវចោទ ដែលគាត់ទំនងជាមានទំនាស់ផលប្រយោជន៍ជាមួយពួកនោះ ។

## ៦. សេចក្តីសន្និដ្ឋាន

59. អាស្រ័យដូចហេតុផលបានអធិប្បាយពីខាងលើ មេធាវីការពារក្តីសូមគោរពសុំស្នើអង្គបុរេជំនុំជម្រះមោឃៈភាពដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដោះលែងលោក **នួន ជា** ជាបន្ទាន់ដោយមានលក្ខខ័ណ្ឌ និង/ឬ ដំណើរការសវនាការលើករណីនេះសារជាថ្មី អោយស្របតាមសិទ្ធិជាមូលដ្ឋានរបស់ **នួន ជា** និងតាមគោលការណ៏ច្បាប់ដែលមានស្រេចអោយបានឆាប់ដូច ដែលអាចធ្វើបាន។ ដើម្បីកុំអោយរាំងស្ទះដល់វឌ្ឍនភាពនៃការស៊ើបអង្កេត លោក **នួន ជា** ស្ម័គ្រចិត្តរស់នៅក្នុងមន្ទីឃុំឃាំងរបស់ អ.វ.ត.ក អោយមានកាធានាសេរីភាពរបស់គាត់ដូចបញ្ជាក់នៅសេចក្តីអំណះអំណាង នៅក្នុងសារណាការពារនេះ។

**មេធាវីការពារលោក នួន ជា**

[signature]

**សុន អរុណ**

00152343

## ឧបសម្ព័ន្ធ ក

## កិច្ចសន្យារបស់ នួន ជា ចំពោះលក្ខខ័ណ្ឌនៃការដោះលែង

១. ខ្ញុំ, **នួន ជា** សូមសន្យាថា ខ្ញុំសុខចិត្ត និងប្រតិបត្តិតាមលក្ខខ័ណ្ឌដូចខាងក្រោម បើសិនជាខ្ញុំដោះលែង ក្នុងលក្ខខ័ណ្ឌក្រោមការត្រួតពិនិត្យរបស់តុលាការដូចតទៅៈ

ក. ខ្ញុំនឹងប្រគល់រាល់ឯកសារដែលស្នើសុំ ទៅអោយអជ្ញាធរ អ.វ.ត.ក។

**ខ.** ខ្ញុំនឹងរស់នៅ ហើយ បន្តស្ថិតនៅក្នុងក្រុងប៉ៃលិន ប្រទេសកម្ពុជា លើកលែងតែ ការធ្វើដំណើរក្នុង ប្រទេសដែលយល់ព្រម និង សម្របសម្រួលដោយអជ្ញាធរ អ.វ.ត.ក។

**គ.** ខ្ញុំនឹងគោរពតាមបំរាមគោចរ និង ស្ថិតនៅក្នុងផ្ទះពី ម៉ោង១០យប់ ដល់ ម៉ោង៧ព្រឹក ហើយ យល់ព្រមនឹងការត្រួតពិនិត្យមិនអោយដឹងជាមុន ពីអាជ្ញាធរ អ.វ.ត.ក ដើម្បីត្រួតមើលវត្ថុមានរបស់ខ្ញុំ។

**ឃ.** ខ្ញុំនឹងបង្ហាញមួយថ្ងៃម្តងទៅការិយាល័យនគរបាល ដែលតាំងនៅកន្លែងខ្ញុំស្នាក់នៅ។

**ង.** ខ្ញុំនឹងមិនធ្វើការទាក់ទងណាមួយជាមួយជនជាប់សង្ស័យ ជនត្រូវចោទ ជនរងគ្រោះ ឬ ជនអាចជាសាក្សី។

**ច.**ខ្ញុំនឹងមិនចូលរួមសកម្មភាពនយោបាយណាមួយ និង មិនទាក់ទងជាមួយសារពត៌មាន និង បណ្តាញផ្សព្វផ្សាយ គ្រប់ប្រភេទ។

**ឆ.**ខ្ញុំនឹងចូលខ្លួននិងមានវត្តមានរាល់ដំណើរការនីតិវិធីពាក់ព័ន្ធជាមួយករណីរបស់ខ្ញុំ និង ឆ្លើយតបភ្លាមៗ ចំពោះរាល់ដីកា ដីការបង្គាប់អោយចូលខ្លួន ដីកាកោះ ដីកាបង្គាប់អោយនាំខ្លួន ឬ សំណើផ្សេងៗ ដែលចេញដោយ អវតក។

ធ្វើនៅថ្ងៃទី13.... ខែវិច្ឆិកា ឆ្នាំ២០០៧ ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា



នួន ជា(ជនត្រូវចោទ)